N° 8 — Reçu le 1er-4-52
"Cossak neavaddey"
INDOCHINE FR… RÉGIE DÉPÔT LÉGAL

# ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ៤ លេខ ៨

Avril

ខែ ឧសភា ព.ស. ២៤៩៥

Mai

ឆ្នាំសិក្សា ១៩៥១-១៩៥២.

# ព្រះរាជាណាចក្រកម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង

ទំព័រ


ឧត្តមដ្ឋាន - មជ្ឈិមដ្ឋានទី ២ ភាសា ........................ ៣

មជ្ឈិមដ្ឋានទី ១ អាទិកដ្ឋាន ភាសា ........................ ១១

កុមារដ្ឋាន - បរិវច្ឆណដ្ឋាន ភាសា ........................ ២៩

អាទិកដ្ឋាន – មជ្ឈិមដ្ឋានទី ១ – នព្វន្ត – រង្វាស់រង្វាល់

រណីមាណសាស្ត្រ ........................ ៣៧

កុមារដ្ឋាន បរិវច្ឆណដ្ឋា - នព្វន្ត - រង្វាស់រង្វាល់ ........................ ៤៥

អាទិកដ្ឋាន - មជ្ឈិមដ្ឋានទី ១ - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ ...... ៦៥

បរិវច្ឆណដ្ឋាន - កុមារដ្ឋាន - វត្ថុស្វាធ្យាយន៍ វិធីបង្ការរោគ ........ ៧៦

លោកទីតិ សំរាប់គ្រប់ថ្នាក់ ........................ ៨២

មេសូត្រត់មាត់ ........................ ៨៨

CENTRE ROYAL DE DOCUMENTATION & D'EDITION
BIBLIOTHEQUE

| Inventaire | | Date | 8-8-63 |
|---|---|---|---|
| CDU | | Cote | |

# ឧត្តមដ្ឋាន

## អាជីវកម្ម

ការដែលមនុស្សយើងមានជីវិតយឺនយូរ ហើយមានសេចក្តីសុខកាយសប្បាយចិត្តបាននោះ គោងអាស្រ័យការបរិភោគនឹងមានវត្ថុផ្សេង ៗ ដែលមាននៅក្នុងលោក ។ វត្ថុអស់នោះមានចំពូកខ្លះរកបានច្រើន តាំងមានចំនួនច្រើនរកងាយ ដូចជាអាកាសជកដង្ហើមរមែងប្រើគ្រប់គ្រាន់មិនខ្វះខាត នៅទីណាក៏មានគ្រប់អន្លើ យើងមិនបាច់នឿយហត់ដើររកទេ ជាវត្ថុសាធារណៈដេរដាសសល់ផល ។ តែវត្ថុចំពូកខ្លះមានចំនួនតិចជាងសេចក្តីត្រូវការរបស់មនុស្ស ត្រូវតែយើងប្រឹងខ្វល់ខ្វាយរកទើបបានមក ។

វត្ថុចំពូកនេះយើងហៅថាទ្រព្យ ។ ពាក្យថាទ្រព្យមានពីរយ៉ាងគឺ ភោគទ្រព្យ បានខាងអាហារចំណីផ្សេង ៗ រួមហៅថា គ្រឿងបរិភោគ នូវគ្រឿងសំពប់ប្រើប្រាស់ផិតខ្លួនរួមហៅថាជាគ្រឿងឧបភោគ ហើយនឹងធនទ្រព្យបានខាងមាសប្រាក់ពេជ្រនិលចិន្តានានា ។ ទ្រព្យអស់នេះយើងត្រូវតែប្រឹងខ្នះខ្នែងប្រើកំឡាំងកាយនឹងកំឡាំងទ្រព្យជាដើមទុន ទើបបានមកបរិភោគប្រើប្រាស់ ។ ការស្វែងរកទ្រព្យដើម្បីយកចិញ្ចឹមជីវិតនឹងទំនុកបំរុងសេចក្តីសុខកាយសប្បាយចិត្តនេះហើយហៅថា "អាជីវកម្ម"

**ការចិញ្ចឹមជីវិតនេះជារបស់សំខាន់បំផុត ក្នុងជីវិតរបស់មនុស្ស**

ឡើង ហេតុដែលមនុស្សយើង មានក្រក៏មានសេចក្ដីសុខទុក្ខផ្សេងៗ គឺព្រោះរបរចិញ្ចឹមជីវិតនេះឯង អ្នកឯណាមានសេចក្ដីខ្នះខ្នែងទស្វាហាប់ ព្យាយាមច្រើន មានចំណេះចេះដឹងប៉ិនប្រសប់ក៏រកទ្រព្យបានច្រើន ទៅជាអ្នកមានស្ដុកស្ដម្ភជាសេដ្ឋីគហបតី ។

(សេចក្ដីសំរាំងលោក ប. ឈុំ)

## ពាក្យពន្យល់

អាជីវកម្ម – (ម.ថ អាជីវៈកាំ) ការចិញ្ចឹមជីវិត

ភោគទ្រព្យ – គឺគ្រឿងបរិភោគដូចជាចំណីអាហារផ្សេងៗ

ឧបភោគ – (ម.ថ អ៊ុបៈភោគ) គឺគ្រឿងសំរាប់ប្រើប្រាស់ជិតខ្លួន (ជាគូគ្នានឹងបរិភោគ)

និលប្ឫនិលចិន្តា – ត្បូងថ្មមានពណ៌ខៀវ

វេវចនៈ – ទ្រព្យ = វត្ថុ - ធនធាន - សម្បត្តិ - ភោគ

សិទិសសត្ថុ – ទុន - ន. ដើមទុន ខាតទុន) (ប្រាក់ដើម) ។

ទន់.គុ.ទីទៃពារ៉ឹង. សាច់ទន់ ។

អក្ខរាវិរុទ្ធ: ឃឹតឃូរ ( រ ) អាស្រ័យ ( ័ ) . ទ្រព្យ . (ព្យ) តេជ្រ (ជ្រ) ។

# អំពីមុខការ

មនុស្សយើងពល់រូបរស់នៅបានដោយអាហារ ទើបត្រូវតែស្វែងរកអាហារមកចិញ្ចឹមជីវិត ដោយប្រកបកិច្ចធុរៈតាមបេះដឹងនឹងសេចក្ដីគាប់ចិត្តរបស់ខ្លួន តែចិត្តរបស់មនុស្សយើងនេះផ្សេង ៗ គ្នា ហេតុនោះនឹងប្រកបកិច្ចធុរៈប្រភេទជាមួយគ្នាតែទាំងអស់ក៏មិនបាន ។ កិច្ចធុរៈមានច្រើនប្រភេទ មនុស្សម្នាក់ ៗ នឹងធ្វើឲ្យសព្វគ្រប់ប្រភេទក៏ពុំបាន ទើបតោងញែកចែកមុខគ្នា ធ្វើដោយមុខ ដោយយ៉ាងទៅ ដូចយ៉ាងមុខការប្រដៅ មុខការរាជការ មុខការលក់ដូរ មុខការស្រែចំការ មុខការចំណែកខ្លួនជាដើម រួមសេចក្ដីទៅថា មនុស្សយើងរមែងមានមុខការសម្រាប់ខ្លួនពល់រូប ៗ ហេតុនោះ សេចក្ដីអាចសមតាមមុខការ ទើបជាកិច្ចដែលត្រូវប្រាថ្នា កាលមានមុខការយ៉ាងណា ក៏អាចចាត់ធ្វើឲ្យសមមុខការយ៉ាងនោះ មានដើមថាជាអ្នកប្រសប់ល្អិតល្អ មានសេចក្ដីបេះដឹងករណីយកិច្ចតូចធំ ក្នុងមុខក្រសួងរបស់ខ្លួនសព្វគ្រប់ ហើយបដិបត្តិទៀងត្រង់ក្នុងមុខក្រសួង រក្សាមុខការឲ្យរៀបរយជាដំកប មិនបណ្ដែតបណ្ដោយឲ្យការងាររសល់រល់ ទាំងតោងគិតកែខ្ជួសជុល បំពេញឲ្យចំរើនជឿនទៅមុខជាទីតាំងប្រយ័ត្នរាំងមិនឲ្យសាបសូន្យថយចុះ ដូច្នេះគួររាប់ថា

**អាចសមតាមមុខការ ។ (សេចក្ដីសំរាំងណោគ ប-ឈុំ)**

## ពន្យល់ពាក្យ

មុខការ = ន. ការដោយមុខ – ដោយឡែកពីគ្នា

ជីវិត – ន. អាយុ – ដំណើររស់នៅ ។

កិច្ចការ: – ការរវល់ – អំពើដែលត្រូវធ្វើ

ករណីយកិច្ច – កិច្ចដែលត្រូវតែបំពេញ ដែលត្រូវធ្វើ

បដិបត្តិឬប្រតិបត្តិ – ន ឬ កិ. ការប្រព្រឹត្ត កាន់-ធ្វើតាម

រោចន – គាប់ចិត្ត – ត្រូវចិត្ត – ពេញចិត្ត ។

សនិសសព្ទ: សូន្យ-គុ – សូន្យឈឹង ។ សូន – កិ – សូនរូបក្រមួនសូនរូបម្សៅ ។

អក្ខរាវិរុទ្ធ: គេទ (ទ) – លក់ដូរ (រ) – គ្រប់សព្វ (ព្វ) មនុស្សប្រុសប់ (ប់) – បដិបត្តិ (ត្តិ) - សាបសូន្យ (ន្យ)

---

មជ្ឈិមដ្ឋាន ទី ២

## ស្ពានមុនីវង្ស

នៅវេលាដែលរថយន្តបត់វង់ កុងតាមផ្លូវកោងកាត់ភូមិច្បារអំពៅ សំដៅទៅទីក្រុងភ្នំពេញ បើអ្នកដំណើរងាកមើលទៅខាងលិច នឹងជាប់

ក្អែកនៅលើគួកង៍របស់មួយសទុង ដែលលេចចេញផុតពីចុងព្រឹក្សា ទាំងឡាយ ៗ របស់នោះហាក់កាន់តែកើនខ្ពស់ឡើងនៅវេលាដែលគេកាន់តែទៅជិត ៗ អ្នកដំណើរដែលពុំសូវធ្លាប់ស្គាល់ទីក្រុងមិនសូវធ្លាប់ឃើញរបស់ចំឡែកថ្មីៗ កើតមានសេចក្តីកើបក្នុងចិត្តផ្សិតឆ្ងល់នឹងតួចំឡែកនោះ ជួនកាលលិចឡើងជាសណ្ឋានដំបូលស្រួចខ្ពី ជួនកាលវែងរពើតរពើង ឧបមាដូចជានាគមួយធំសម្បើម ៗ សេចក្តីសង្ស័យរលត់បាត់មួយរំពេច ដោយយល់ជាក់ថាជាស្ពានគឺស្ពានមុនីវង្សដែលពដការបានសង់រួចមកជាង៍ម្ភៃឆ្នាំហើយ ៗ ស្ពាននេះវែងបណ្តោយបីរយម៉ែត្រ សង់ឆ្លងកាត់ទន្លេទប់ទល់តនឹងទឹកហូរខ្លាញ់ក្បួបគ្រុបាញ់ក្នុងរដូវវស្សា ៗ ស្ពាននេះបំកោង៍ទ្រុង៍កណ្តាល មានភាពជាស្នាមួយធំក្រៃលែងដែលយឹតកោង៍មកហើយដោយដៃព្រានព្រៃដ៏មានឫទ្ធិ ៗ ដំបូលកណ្តាលខ្ពស់លវែលហាក់នឹងសង្កត់ស្ពានទាំងមូល ទំលាក់ទម្ងន់ទៅលើចុងសងខាងឲ្យជ្រែងជាប់នៅ ៗ របស់ទាំងអស់ដែលកាត់ខ្វាត់ខ្វែងទាញទង់យឹតយោងទប់កម្លាំងគ្នាទៅវិញទៅមក ៗ បណ្តោយស្ពានចែកជា បីសង្កាត់ កណ្តាលធំទូលាយសំរាប់ឲ្យយានជំនិះផ្សេង ៗ បើកបរ សងខាងជាផ្លូវសំរាប់ឲ្យអ្នកថ្មើរជើងមានបង្កាន់ដៃជារបាំង ៗ គេនឹកអស្ចារ្យនឹងទម្ងន់ផ្នែកដែកធំមួយៗ ដែលអាចលើកដាក់ផ្គុំផ្គុំគ្នាឡើង ជាតួស្ពានមួយយ៉ាង

សម្បើមយ៉ាងល្អឯកនៅស្រុកខ្មែរ ។ គឺដោយហេតុតែស្ពាននេះហើយ ដំណើរទៅមកនៃអ្នកស្រុកខាងត្រើយភ្នំពេញ និងអ្នកខាងត្រើយម្ខាងនៃ ទន្លេបាសាក់ធ្វើបានដោយស្រួល ។ ស្ពាននេះជារបស់មានប្រយោជន៍ យ៉ាងសំខាន់ ដល់ការដឹកនាំផលប្រយោជន៍ក្នុងស្រុក ឬក្រៅស្រុកចូល ទៅទីក្រុងភ្នំពេញ ។

(សេចក្ដីសំរាំងលោក ប - ឈុំ)

## ពន្យល់ពាក្យ

សទ្ទុង = សខ្ពស់វែង

រពើតរពើង = ជម្រាលស្ពានមិនស្មើ គឺខ្ពស់ទាបខ្ពស់ទាប ។

ឫទ្ធិ = (ម - ថ - រិត). ន. អំណាច.

លវែល = វែលវែងស្រលួត.

ផលប្រយោជន៍ = ទំនិញឬធនធានកើតឡើងពីព្រះធរណី ...

រចនៈ = ភាព = បែបបទ - លំនាំ - ឫកពារ - សណ្ឋានទ្រង់ទ្រាយ ។

សទិសបទ = លេច.កិ. លេចសំដី ។ លេច គុ. ក្អមលេច ។ លេច ន. ដំបៅលេច ។ លិច. កិ. ថ្ងៃលិច ។ លិច.ន ទិសខាងលិច ។

អក្ខរាវិរុទ្ធ = រថ (ថ) នាគ (គ) ហូរ (រ) វស្សា (ស្សា) ពុទ្ធិ (ទ្ធិ) ថ្មើរ (រ) ។

# របរជារបស់សំខាន់

មានយុវជនជាច្រើនដែលមើលឃើញច្បាស់ ឬនឹកមិនឃើញថា របរជារបស់សំខាន់ត្រឹមណា ព្រោះមាតាបិតាឬអ្នកគ្រប់គ្រងជាអ្នករកជាអ្នកធ្វើ យកមកចិញ្ចឹមយើងៗគ្រាន់តែជាអ្នកស៊ីអ្នកប្រើប្រាស់ទើបថាជាការស្រួលសប្បាយ តែថាបើគិតឲ្យជ្រៅបន្តិចទៅ នឹងយល់ច្បាស់ថា គ្រឿងស៊ីគ្រឿងប្រើអស់នោះ លោកបានមកដោយខំធ្វើការអាជីវកម្មទាំងអស់ ៗ ប្រសិនបើឈប់ធ្វើការចិញ្ចឹមជីវិតកាលណា គ្រឿងស៊ីគ្រឿងប្រើក៏គ្មាន ទុកជាមានរបស់ចាស់សេសសល់នៅខ្លះក៏គង់រេចរិលអស់ទៅជាលំដាប់ ៗ ហេតុនេះត្រូវតែយុវជនយើងជួយមាតាបិតាឬអ្នកអភិបាលខ្លួនធ្វើការងារផ្សេងៗតាមកម្លាំងនឹងកាលវេលា ព្រោះយើងធំឡើងត្រូវតែធ្វើការងារ ដើម្បីចិញ្ចឹមខ្លួនគ្រួសាររបស់ខ្លួននឹងមាតាបិតាតបស្នងសងគុណអ្នកមានគុណជាដើមតទៅទៀត ។ កិច្ចអស់នេះយើងជៀសវាងមិនរួច ហើយសង្ឃឹមពឹងអ្នកដទៃតែម្យ៉ាងក៏មិនបានដែរ មាតាបិតាក៏កាន់តែចាស់ជរាទៅរាល់ថ្ងៃ យើងត្រូវតែធ្វើការងារជំនួសលោកដើម្បីដំកល់វង្សត្រកូលឲ្យចំរើនឡើង ទើបសមនឹងមុខក្រសួងខ្លួន ដែលជាបុគ្គល្អ ដែលលោកហៅថា អតិជាតបុត្ត ។

(សេចក្តីសំរង់លោក ប - ឈុំ)

# ពន្យល់ពាក្យ

យុវជន= (ម. ថ. យុវៈជន) ជនកំលោះ (ក្មេង)

អភិបាល= (ម. ថ. អៈ...) បីបាច់រក្សា ...

អតិជាតបុត្ត ឬបុត្រ= (ម. ថ. អៈតិជាតៈបុត្ត) កូនប្រសើរកន្លង.

វេវចនៈ= សំខាន់=ប្រសើរ ថ្លៃថ្លា លើសលែង បំណាន ...

សទិសសព្ទ= គុណ–ន–គុណមាតាបិតា ។ គន់ –ក– គន់មើល

គុន ន គុនដំបង ។

អក្ខរាវិរុទ្ធ= ការងារ (រ) គុណ (ណ) ចៀស ឬជៀស វង្ស (ង្ស)

សួរទោទ.– របរអ្វីខ្លះដែលធំជាងគេនៅស្រុកយើង ។ អ្នកយល់ឃើញថារបរទាំងឡាយជាការស្រួលសប្បាយ ឬដូចម្តេច ។ ពីព្រោះអ្វី ។ មាតាបិតាអ្នកធ្វើរបរអ្វី ។ លុះអ្នកធំឡើងអ្នកត្រូវតបគុណមាតាបិតាយ៉ាងណាវិញ ។ល។

---

មជ្ឈមដ្ឋានទី ១

## រៀនមើល-ហាត់ភាសា

# ព្រះមហាក្សត្រនឹងប្រជាជន

ព្រះមហាក្សត្រដែលទ្រង់គ្រប់គ្រងប្រទេសនីមួយ ៗ ព្រះអង្គជាទេពតាដោយសន្មត ទ្រង់ព្រះនាមថា "ព្រះរាជា" ព្រោះទ្រង់ប្រកបដោយការសង្គ្រោះ ប្រជាជនដោយសង្គហវត្ថុ ៤ យ៉ាង គឺប្រទានទេយ្យវត្ថុ – មានព្រះវាចាគួរឲ្យចង់ស្តាប់ – ទ្រង់ប្រព្រឹត្តអំពើជាប្រយោជន៍ – ទ្រង់តាំងព្រះអង្គស្មើ ៗ គឺប្រើបុគ្គលឲ្យល្មមពេញចិត្តប្រជាជន ។

ទ្រង់គម្រង់ប្រជាជន ដោយទសពិធរាជធម៌ ធម៌សម្រាប់ព្រះរាជាមានដប់យ៉ាងគឺ អំណោយទាន – រក្សាសីលប្រាំជានិច្ច – បំណាយព្រះរាជទ្រព្យទំនុកបំរុងប្រទេស - មានសេចក្តីទៀងត្រង់ - ទន់ភ្លន់សុភាព - រក្សាឧបោសថសីលតាមកាលកំណត់មួង ៗ – មិនកំដៅក្រហាយប្រជាជន - មិនបៀតបៀនអ្នកដទៃ – មានសេចក្តីអត់ធន់ – មិនបំពានលើធម៌លើច្បាប់ ។

ដោយហេតុនេះទើបទ្រង់ព្រះនាមថា ជាបុព្វការីរបស់ប្រជាជន ។ ប្រជាជនដែលបានសេចក្តីសុខដោយសារការគ្រប់គ្រងរបស់ព្រះរាជានោះ ហើយជាអ្នកដឹងឧបការគុណក៏តាំងចិត្តស្មោះត្រង់ចំពោះរាជការផែនដី ជួយយកអាសាការផែនដីដោយស្មោះស្ម័គ្រ មានស្វាមីភក្តិចំពោះព្រះរាជា ចំពោះរាជការផែនដី ឥតមានរំងើងទើងឲ្យទាស់ផ្លូវរាជការ យ៉ាងនេះហៅថា កតញ្ញូកតវេទីចំពោះព្រះរាជា ជាម្ចាស់ជីវិតរបស់ខ្លួន ។

ព្រះពុទ្ធឃោសាចារ្យជ.ណាត.

(សេចក្ដីសំរាំងលោកអុំ - ឈុំ)

# អាននិងពន្យល់ពាក្យ

សង្គហវត្ថុ = (អ ថ.សង់គៈហៈ) ន. អង្គនៃសេចក្ដីសង្គ្រោះ មាន ៤ យ៉ាង...

ទេយ្យវត្ថុ – (អ.ថ.ទ័យយៈ) ន. វត្ថុទុកធ្វើជាទាន ។

ទសពិធ ឬ ទសពិធរាជធម៌ – (អ ថ.ទៈសៈពិធៈរាជៈធ័រ) ន.– គឺធម៌ ១០ ប្រការសម្រាប់ព្រះរាជា ។

សីល – ការកាន់ ឬ ប្រព្រឹត្តល្អដោយកាយវាចា...

ឧបោសថសីល – (អ ថ.អ៊ុពោ៉សុតបៈសីល) សីលឧបោសថ, សីលសម្រាប់រក្សាជំរះចិត្ត ។

បុព្វការីរបស់ប្រជាជន – បានធ្វើសេចក្ដីទំនុកបំរុងផ្គង់ផ្ដើមដល់ប្រជាជន ។

យកអាសា – ជួយឈឺឆ្អាលដោយស្ម័គ្រស្មោះអស់ពីចិត្តពីថ្លើម

ស្វាមីភក្ដិ – (ស្វាមី – ម្ចាស់ – ប្ដី)– ស្វាមីភក្ដិ – សេចក្ដីស្រឡាញ់ស្មោះចំពោះម្ចាស់ ។

វេវចនៈ ឃុកពា – មារយាទ កិរិយា - បែបបទសណ្ដាប់ធ្នាប់ ។

សទិសសព្ទ: ធន់ – ទ្រាំ . ធន់ធ្មឹង ៗ ធន – ទ្រព្យ - ធនធាន

ធុន – បែបយ៉ាងកំណើតជាមួយគ្នា, កែវមួយធុន ៗ

សួរ:១ – ព្រោះអ្វីបានជាថាព្រះមហាក្សត្រជាទេពតាដោយសន្មត ដែលទ្រង់ព្រះនាមជារាជានោះ គឺទ្រង់ប្រកបដោយការអ្វីខ្លះ? ធម៌សម្រាប់ព្រះរាជាមានប៉ុន្មានយ៉ាង? ប្រជាជនត្រូវប្រព្រឹត្តដូចម្ដេចចំពោះព្រះមហាកក្សត្រ? ។ល។

## រៀនមើល-សរសេរតាមសូត្រ

# អតីតប្រវត្តិនៃប្រទេសកម្ពុជា

កាលនោះមានលាវម្នាក់លើកព្យុហសង្គ្រាមមកដណ្ដើមយកប្រទេសកម្ពុជា ៗ លាវនោះតាំងខ្លួនជាក្សត្រិយ៍មួយព្រះអង្គតាំងជាតិស្យាមប្រទេស គឺជាតិសៀមនាំបណ្ដាលហេតុឡើងទើបលាវហើយនឹងយួនដែលធ្លាប់ចំណុះចុះចូលប្រទេសកម្ពុជាពីដើម ក៏កើតចិត្តតាមសៀមហើយដណ្ដើមយកដែនដីប្រទេសកម្ពុជានេះ ដោយចំណែកសាមលពង្សប្រទេសពង្សផ្សេង ៗ ក៏លែងចំណុះចុះចូលប្រទេសកម្ពុជានេះ ចាប់តាំងពីគ្រានោះមក ៗ ប្រទេសខ្មែរក៏ទៅជាដែនដីតូចស្ដួចស្ដើងអាណាប្រជានុរាស្ត្រក៏ក្រីក្រពិបាករៀងមក ៗ

ផល់មកផែនដីព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះបាទ សម្ដេចព្រះនរោត្តមបរមរាមាទេវាវតារ ទ្រង់ប្រកបដោយមហាករុណា ដល់អាណាប្រជានុរាស្ត្រ ដែលក្រីក្រពិបាកដោយស្រុកបាក់បែកទឹង សឹកសង្គ្រាមជាយឿយ ៗ នោះណាស់ ជំនុំព្រមក្សត្រិយ៍សេនាបតី ទ្រង់ មានព្រះសុភអក្សរទៅចងសម្ពន្ធមិត្រនឹងមហានគរបារាំងសែស ។

អក្ខរាវិរុទ្ធ— ព្យុហ (ហ) សាមលពង្ស (ង្ស)

ប្រទេសពង្ស (ង្ស) – អាណាប្រជានុរាស្ត្រ – មហាករុណា – សុភអក្សរ សម្ពន្ធមិត្រ ។

---

## ការពិភាក្សា

### បង្រៀនពាក្យនិងភាសា

### អាទិត្យទី ១.– អំពីលោហធាតុ (ធាតុដែក)

នាម-ដែក ស្ពាន់ សំណ សំរិទ្ធិ លង្ហិន ទង់ដែង ដែកស៊ីឡាត

ដែកស័ង្កសី ប្រាក់មាស ទង់ហ្គី ។

គុណនាម .— រឹង ទន់ ស្រួយ ជាប់ មាំ ធ្ងន់ ស្រាល ប្រេះ បាក់ បែក ក្តៅ ត្រជាក់ រលីង រលោង រលើប គ្រាស់ ស្តើង ខ្មៅ ស ក្រហម លឿង ប្រផេះ ភ្លឺ ស្រអាប់ ។

កិរិយាសព្ទ .— ដុតដែក វាយដែក (ដំ) រំលាយមាស កាត់ស្ពាន់ ផែទង់ហ្គី ផ្សារមាស ថ្លឹងសំណ ហូតលួស ។

ហាត់ភាសា .— ក្រៅអំពីធាតុឈើទឹងធាតុថ្ម មានធាតុអ្វីទៀត ? គឺអ្វីខ្លះដែលរាប់បញ្ចូលក្នុងពួកធាតុដែក ?

ធាតុដែកអ្វីដែលមានដម្លៃជាងគេ ? ព្រោះអ្វី ? ឯដែកមានប្រយោជន៍ឬទេ ? ព្រោះអ្វី ? អ្នកបានឃើញគេយកប្រាក់ទឹងមាសទៅធ្វើជាវត្ថុអ្វីខ្លះ ?

ការហាត់សរសេរ .— ចូររើសយកពាក្យខាងក្រោមនេះដាក់បំពេញឃ្លានៅកន្លែងចន្លោះពងត្រី ៖ ដែក - ស្ពាន - ទង់ដែង - មាស - ប្រាក់ - សំណ - រឹង - ទន់ - មាំ - ក្រហមឆ្អៅ ៖

មនុស្សយើងត្រូវការ ..... (ដែក) យកមកធ្វើជាគ្រឿងប្រើប្រាស់គ្រប់ជំពូក ព្រោះជាជាតិ .....(រឹង) ហើយ .....(មាំ) ផង ។ ឯស្រី ៗ ស្រឡាញ់តែ .....(មាស - ប្រាក់ - ទង់ហ្គី) យកមកធ្វើជាគ្រឿងអលង្ការ ឯពជការផែនដីត្រូវការ ......(ប្រាក់ - មាស - ទង់ដែង) យកមកធ្វើជារូបិយវត្ថុសំរាប់ចាយ ។

នៅប្រទេសបារាំងរាជការបង្កើតឲ្យមានរូបិយវត្ថុដែលមានដម្លៃបំផុត ធ្វើនឹង......(មាស) ឯ ...(សំណ) គេយកទៅធ្វើជាបំពង់ទឹក ព្រោះវា ...(ទន់) ស្រួលពត់បត់បែនចុះឡើងបាន ។

## អំពីជាងដែក

នាម.– ដើងក្រាន ស្នប់ ទ្រនាប់ ដង្កាប់ ញ្ញួរ ថ្មសំលៀង ពាងទឹក ស្នាប ដើងម៉ា ដែក កំរិត ពូថៅ ចប ប៉ែល ។

គុណនាម.– សន្លោសន្លៅ ស្រអាប់ ជ្រាយ រឹង កោង ត្រង់ មុត ។

កិរិយាសព្ទ.– សម់ភ្លើង ដុតដែក កាត់ដែក ប្រុងកំបិត ផ្គុំពូថៅ សំលៀងចប លត់ពន្លាក ។

វិធីហាត់ភាសានិងហាត់សរសេរ– សុំឲ្យធ្វើតាមរបៀបដែលធ្វើមុន ។

### បង្រៀនមើល

១– អំពីដែក.– (សៀវភៅវត្ថុស្គាល់ព្យាយន៍បរិវត្តណាដ្ឋានទំព័រ ៨៨

២– អំពីលោហធាតុ – ជាងដែក - ជាងស្ពាន់ស - ជាងទង (សៀវភៅវិត្តស្វាធ្យាយន៍អាទិកដ្ឋានទំព័រ ១២៧) ។

## សរសេរតាមសូត្រ

### អំពីលាយលោហធាតុ

អស់ទាំងលោហធាតុដែលនៅក្នុងដីទាំងប៉ុន្មាន ជួនណាសុទ្ធជួនណាលាយនឹងធាតុឯទៀត តាមធម្មតាលោហធាតុសុទ្ធពុំសូវប្រើការតែឯកឯងទេ គេត្រូវយកមកលាយនឹងធាតុឯទៀតទើបប្រើការបាន ។

ឯលោហហធាតុដែលគេប្រើការក្នុងគ្រឿងដែកនោះគឺស្ពាន់-ស័ង្កសីសំណនឹងសំណប៉ាហាំង ។ ស្ពាន់ជាលោហធាតុព័ណ៌ក្រហម កាលណាត្រូវទឹកម្ជូរឬទឹកខ្ទិះទៅមានច្រេះចាប់ឯច្រេះនេះជាថ្នាំពុលពូកែណាស់ហេតុនេះត្រូវដុសលាងសំអាតឆ្នាំងស្ពាន់ឬវែកស្ពាន់ដែលប្រើការក្នុងផ្ទះបាយឲ្យស្អាតជានិច្ច ដើម្បីកុំឲ្យមានច្រេះឬដុះស្និម ។

ស័ង្កសីជាធាតុមានព័ណ៌សខៀវ (ព័ណ៌ប្រផេះ) សម្រាប់ធ្វើជាប៉ោតដងទឹក ប៉ោតស្រោចដំណាំ ស្នូកឆ្លូតទឹក ទបង់ទឹក ហើយនឹងប្រក់ផ្ទះ គេយកដែកមកលាយនឹងធាតុនេះ ដើម្បីកុំឲ្យច្រេះចាប់ ។

សំណាញ់ហាំងជាធាតុស គេកិនធ្វើជាស្លឹកស្តើងៗបាន គេហៅជា ស្លឹកសំណាញ់ហាំងសំរាប់ខ្ចប់ចំណីអាហារ ។

អក្ខរាវិរុទ្ធ– សុទ្ធ– ឯកឯង ទឹកឃ្មុរ ដុសលាង ដុះស្នឹមទបង្គ្រទឹក ។

## តែងសេចក្តី

ចូរអធិប្បាយអំពីធាតុដែកតាមពាក្យចោទខាងក្រោមនេះ ៖

របស់អ្វីខ្លះដែលចូលមកក្នុងពួកធាតុដែក (លោហធាតុ) !

ធាតុដែកកើតមកពីអ្វី ? ព័ណ៌យ៉ាងដូចម្តេចខ្លះ ? គេឃើញមាននៅឯណា ? គេធ្វើដូចម្តេចខ្លះទើបបានរបស់នោះយកមកប្រើការគ្រប់ចំពូក ? អ្នកចូលចិត្តរាប់អានធាតុដែកឬទេ ? ព្រោះអ្វី ? ។

## អក្សរផ្ចង់

ង ផ ឌ ជ ងេងើ ងេងងោង ងគុយ ជេក ផ្ទូងក៏
ជើរផ្ទុង ឌកឌង្គើមធើតផត

## បង្រៀនពាក្យ - និងភាសា

## អាទិត្យទី ២.- អំពីផលប្រយោជន៍ដែក

នាម.– កាំបិត ដឹង ពូថៅ រណារ ពន្លាក ដែកស្វាន ដែកគោល ដែកខ្វង ញញួរ ដង្កាប់ ក្រឹប ចប ប៉ែល ផាល ម៉ាស៊ីន កប៉ាល់ រថយន្ត យន្តហោះ ប្រវ៉ាក់ យុថ្កា ស្ពាន់ ។ល។

គុណនាម.– មុត រិល ថែប ស្រួច ទាល មូល សំប៉ែត តូច ធ្លារ មាំ ស្វិត យឺត កោង ត្រង់ ។

កិរិយាសព្ទ.– ពត់មុខរណារ ឆាបរណារ អារឈើ ពុះឧស សំលៀងពន្លាក វាយដែកគោល ដាក់ដងកាំបិត ឈូសឈើ ដកដែកគោល ដំដែក បោះយុថ្កា ។ល។

ហាត់និយាយ.– របស់អ្វីខ្លះដែលធ្វើអំពីដែក ? ។ នៅផ្ទះអ្នកមានប្រដាប់ប្រើប្រាស់អ្វីខ្លះដែលធ្វើអំពីដែក ? កាំបិតសម្រាប់ប្រើការអ្វី ? ពូថៅ - ពន្លាក - រណារ - ដឹង ។ល។ សំរាប់ប្រើការអ្វី ? ។

ការហាត់សរសេរ.– ចូរតែងជាឃ្លានឹងពាក្យខាងក្រោមនេះ៖

កាំបិត - រណារ - ពន្លាក - ដែកគោល - ញញួរ ។

## ២– អំពីផលប្រយោជន៍ស្ពាន់

នាម.– រូបិយវត្ថុ គ្រឿងម៉ាស៊ីន គ្រឿងអលង្ការ ខ្សែលួស នាឡិកា ឆ្នាំងខ្ទះ ឆ្នាំងអ៊ុត ស្លាបព្រា សម កណ្ដឹង គង រគាំង

ផ្លូង ចង្ក្រាន ព្រះពុទ្ធរូប រូបផ្សេង ៗ ប្រអប់ អកកំបោរ ហ៊ិបស្លា សោហ៊ិប ត្រចៀកហ៊ិប គោម ចង្កៀង កន្តោរ ។ល។

**គុណនាម.** ក្រហម ស ខ្មៅ ភ្លឺ ស្រអាប់ រឹង មាំ ល្អ អាក្រក់ ពៀច ថោ៉ន ទ្រុត ។

**កិរិយាសព្ទ.–** រំលាយស្ពាន់ សិតរូបផ្សេង ៗ ខាត់ផ្លូង ដូតគុ ដាក់ត្រចៀកហ៊ិប - ប្រអប់ ។

**ហាត់ភាសានិងហាត់សរសេរ.–** (សូមធ្វើដូចមុន)

## បង្រៀនមើល

១– សំណ - ស្ពាន់ - ស្ពាន់លឿង

(សៀវភៅវិទ្យាសាស្ត្រ បរិច្ឆណដ្ឋាន ទំព័រ ៩៣ មេរៀនទី ១១) ។

២– អំពីលោហធាតុ ដានដែក - ដានស្ពាន់ - ដានទង

(សៀវភៅវិទ្យាសាស្ត្រ អាទិកដ្ឋានទំព័រ ១២៦) ។

សុំឲ្យកែជម្រូវពាក្យខ្លះដូចខាងក្រោមនេះ ៖

ទី ១– កំប៉ិត = កាំបិត ។ ដុះ = ដុស (ដុសឲ្យស្អាត-ឲ្យភ្លឺ) អំពង់ = បំពង់ ។ ប្រយ៉ាត់ = ប្រយ័ត្ន ។

ទី ២– ចង្ក្រាន = ជើងក្រាន សា = ស (សក្បុស) ។

សង្កសី = ស័ង្កសី ។

# តែងសេចក្តី

១– ចូរអ្នកអធិប្បាយអំពីផលប្រយោជន៍ដែកតាមពាក្យចោទខាងក្រោមនេះ ៖

នៅស្រុកខ្មែរយើងគេយកដែកពីកន្លែងណាមក? អ្នកឃើញគេយកដែកមកប្រើការដូចម្តេចខ្លះ? អ្នកចូលចិត្តរាប់អានដែកឬទេ? ព្រោះអ្វី?

២– ចូរអ្នកអធិប្បាយអំពីជាងដែកតាមពាក្យចោទខាងក្រោមនេះ៖

នៅក្នុងភូមិអ្នកមានជាងដែកឬទេ? ជាងនោះជាតិអ្វី?

រោងជាងនោះនៅត្រង់ណា? នៅក្នុងរោងនោះមានរបស់អ្វីខ្លះ? មានមនុស្សធ្វើការចំនួនប៉ុន្មាននាក់? ក្នុងមួយថ្ងៃៗអ្នកឮស្នូរដូចម្តេចនៅក្នុងរោងនោះ? ជាងដែកមានប្រយោជន៍ដល់យើងឬទេ? ព្រោះអ្វី? អ្នកចូលចិត្តជាងដែកនោះឬទេ? ព្រោះអ្វី? ។

## អក្សរផ្ចង់

ង ផ ជ ជ ឯ ផ្ចូរផង់ ជីជុះផុសកណ្ដាលសទន្លេ ជ្ជូតទឹក ជុសជូតជំរះឲ្យជ្រះក្អែស

នៅឯណា នៅឯណោះ ។

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី ៣.— ១-អំពីផលប្រយោជន៍ប្រាក់

*នាម.- រូបិយវត្ថុ (ប្រាក់រៀល-ប្រាក់កាក់) កងជើង កងក ការ ចិញ្ចៀន ខ្សែក្រវាត់ ខ្សែនាឡិកា ហិបស្លា ជើងពាន តុ វ៉ែក ផ្តិល ។ល។*

*គុណនាម.— សង្ហារ រលើង ម៉ដ្ឋ គគ្រាត គគ្រើម ទន់ រឹង*

*កិរិយាសព្ទ.— រំលាយប្រាក់ ធ្លាក់ក្បាច់ ហូតលួសប្រាក់ ស្អាង ព្រះពុទ្ធរូប វាតកងជើង ធ្វើការ-ខ្សែក្រវាត់ ។*

*វិធីហាត់សរសេរ.— (សំឡៀតែងសេចក្ដីឲ្យសិស្សធ្វើផង) ។*

## ២_អំពីជាងទង

នាម.– អង្គំ តុ ពពាយ មេដែក បង្កៀនខ្វាញ់ ដើងតាំង ដង្គាប់ ដំបៀត ដែកឆ្កើះ ដែកក្រចក ដែកខៃ ដែកឆាប ក្រដាសខាត់ ថាស តម្រង់ប្រាសបំពង់ ។

គុណនាម.– ក្រហមឆ្អៅ ភ្លឺផ្លេក ប្រសប់ រហ័សរហួន ហ្មត់ចត់ ស្អាត ពូកែ នឿយ ធូន់ ស្រាល រួយ ស្រពន់ ស្គម ។

កិរិយាសព្ទ–ខាត់កង់ដៃ បោសកំទេចមាស ដាំត្បូង ឲ្យដីមាស ឆាបទងទំហូ ។ល។

## ៣-អំពីផលប្រយោជន៍មាស

នាម.– ទំហូ កន្លាស់ក ខ្សែដៃ ខ្សែខ្លួន ខ្សែក ស្មៀតសក់ ចិញ្ចៀន ខ្សែនាលិកា ។ល ។

គុណនាម.– រន្ទាលច្រាលឆ្អៅ វែង ខ្លី រលោង រលីប ភ្លឺ ស្រអាប់ សឹក ពៀច វៀច ត្រង់ ។

កិរិយាសព្ទ.– ធ្វើចិញ្ចៀន ឆាបកន្លាស់ក ស្អាងព្រះពុទ្ធរូប ភ្ជាប់-ក្បាច់ស្មៀតសក់ ។

## ៤- អំពីផលប្រយោជន៍សំរិទ្ធិ

នាម. គង រគាំង ផ្តិល ត្បាល់បុកស្វា ពពិល ប្រអប់ កូង សឺមា បង្ក្រង កណ្ដឹង ។ល។

គុណនាម.- រលីង រលើប ខ្មៅព្រឹក ប្រហោង គាន់ ធូន់ ។

កិរិយាសព្ទ.- រំលាយសំរិទ្ធិ សិតគង រគាំង បង្ក្រង កណ្ដឹង ខាត់ត្បាល់បុកស្វា ឆ្លាក់ក្បាច់ពពិល ។

## បង្រៀនមើល

## ១- អំពីប្រាក់-មាស

(សៀវភៅវត្ថុស្វាធ្យាយន៍បរិវច្ឆណដ្ឋានទំព័រ ៩៥)

សុំឲ្យត្រូវពាក្យខ្លះ;-ខ្សែករ=ខ្សែក ។ ពណ៌សរ=ព័ណ៌ស ។ រេចនា=រចនា=(រៈចៈនា) ។

## ២- អំពីការជាងស្មិត

សៀវភៅវត្ថុស្វាធ្យាយន៍អាទិកដ្ឋានទំព័រ ១២៩

ការហាត់និយាយ=ហាត់សរសេរ- (សូមធ្វើដូចរបៀបមុន)

# សរសេរតាមសូត្រ

## ១– អំពីប្រាក់ នឹង មាស

ប្រាក់នឹងមាសជាលោហធាតុមានដម្លៃច្រើនជាងលោហធាតុឯទៀត ប្រាក់សម្បុរសមានដម្លៃរងបន្ទាប់ពីមាសមក គេធ្វើជារបស់សម្រាប់ចាយ នឹងប្រកបការរចនាបានច្រើនយ៉ាង ប៉ុន្តែត្រូវលាយស្ពាន់បន្តិចផង ដើម្បីឲ្យរឹង ។

មាសជាធាតុបរិសុទ្ធ មានសាច់ទន់ស្វិត សម្បុរលឿងជារបស់សម្រាប់ប្រើការធ្វើជាគ្រឿងប្រដាប់កាយ នឹងការរចនាវិចិត្រផ្សេងៗ ឬជួនកាលប្រទេសខ្លះប្រើជារបស់ចាយជំនួសប្រាក់ក៏មាន ។ គេយកមាសទៅប្រើការសុទ្ធតែឯងពុំបានទេ ព្រោះវាទន់ហើយឆាប់សឹកដូចប្រាក់ដែរ ហេតុដូច្នេះបានជាគេលាយនឹងស្ពាន់បន្តិច ប៉ុន្តែត្រូវទុកឲ្យគង់សម្បុរជាមាសដរាប ។

អក្ខរាវិរុទ្ធ · លោហធាតុ – សម្បុរស – ការរចនា – វិចិត្រ – បរិសុទ្ធ ជំនួស – សឹក ។

## ២ អំពីការជាងស្មិត

ជាងស្មិតដុតលោហធាតុឲ្យរលាយទៅជារាវ ហើយគេបង្ហូរទៅ

ក្នុងពុម្ពមួយ ដើម្បីឲ្យមានទ្រង់ទ្រាយតាមពុម្ពនោះជារបស់ផ្សេង ៗ ដល់កាលណាត្រជាក់ទៅ ៗ គេយកដែកស្វិតគឺដែកដែលលាយនឹងធ្យូង-ស្ពាន់ សំណ ស័ង្កសី ទុកសម្រាប់ប្រើការ ៗ

អ្នកស្រុកអាយពុំសូវធ្វើដែកស្វិតទេ ៗ នៅប្រទេសឥណ្ឌូចិនមានគ្រឿងស្វិតរបស់បារាំងសម្រាប់បង្កើតដែកស្វិតបំរុងទុកធ្វើវត្ថុផ្សេង ៗ ដូចជាឆ្នាំងខ្ទះ ឆ្នាំងបាយ ៗ ល ៗ

អក្ខរាវិរុទ្ធ·— វត្ថុការ–បង្ហូរ–ពុម្ព–ទ្រង់ទ្រាយ–ធ្យូង–ស័ង្កសី ៗ

## តែងសេចក្តី

១– ចូរអ្នកអធិប្បាយអំពីជាងទងនៅភូមិអ្នក តាមពាក្យចោទខាងក្រោមនេះ ៖

នៅក្នុងភូមិអ្នកមានជាងទងឬទេ ? ជាងនោះជាតិអ្វី ? ឈ្មោះអ្វី ? ផ្ទះជាងនោះនៅត្រង់ណា ? នៅក្នុងផ្ទះជាងនោះអ្នកឃើញមានរបស់អ្វីខ្លះ? មនុស្សធ្វើការច្រើនឬតិច ? ក្នុងមួយថ្ងៃ ៗ អ្នកឮសូរដូចម្តេចក្នុងផ្ទះជាងនោះ ? អ្នកឃើញគេដាក់គ្រឿងអលង្ការនៅក្នុងអ្វី ? ជាងទងមានប្រយោជន៍ដល់អ្នកទាំងពួងឬទេ ? ព្រោះអ្វី ? អ្នកចូលចិត្តធ្វើជាងទងទេ ? ព្រោះអ្វី ? ៗ

២– ចូរអ្នកអធិប្បាយអំពីអ្នកដឹងដូចម្ដេចខ្លះ ពីគេធ្វើអំបិលតាមអ្នកបានឮគេនិយាយក្ដី ឬតាមអ្នកបានឃើញក្ដី ។

## ទំនងតែង

១ – អំពីស្រែអំបិល (នៅកន្លែងណាមានស្រែអំបិល ? បែបភាពស្រែនោះដូចម្ដេច ? ) ។ ២– អំពីទឹកសមុទ្រ (បែបភាពទឹកសមុទ្រដូចម្ដេច ? មានរសជាតិយ៉ាងណា ? ) ។ ៣– អំពីការដែលគេធ្វើអំបិល (គេបញ្ចូលទឹកសមុទ្រមកក្នុងស្រែដូចម្ដេច ? គេធ្វើដូចម្ដេចទៀត ? ) ។ ៤– អំពីអំបិល( បែបភាពអំបិលដែលនៅក្នុងស្រែ យ៉ាងដូចម្ដេច ? គេធ្វើដូចម្ដេចឲ្យបានអំបិលស្អាត ? ) ។ ៥– ប្រយោជន៍នៃអំបិល ( បង់សម្ល នំ ចំណីប្រឡាក់ ត្រី សាច់ ។ ល ។ ) ។ ៦ យោបល់យល់ឃើញ ។

## គំរូសេចក្ដីទី ២

អំបិលមាននៅគ្រប់ផ្ទះទាំងអស់ លោកគ្រូខ្ញុំមានប្រសាសន៍ថា អំបិលមានពីរយ៉ាង៖ អំបិលសមុទ្រមួយយ៉ាង អំបិលដីមួយយ៉ាង ។

នៅខេត្តប៉ោលាវ បាយដោទីងបារៀក្នុងដីដែនកូសាំងស៊ីនមានគេធ្វើអំបិលនឹងទឹកសមុទ្រជាច្រើន ។

ទីងធ្វើអំបិលនោះ គេធ្វើស្រែបែបភាពប្រហែលស្រែដែលគេដាំស្រូវនេះដែរ ប៉ុន្តែមានភ្លឺក្រៅមាំមួនជាងស្រែស្រូវបន្តិចដើម្បីឃាំងទឹកឲ្យ

ជាប់ នឹងមានភ្លឺក្នុងកាត់ខ្វាត់ខ្វែងជាច្រើនសម្រាប់ដើរទៅកើបយកអំបិល បានដោយងាយ ។

ទឹកសមុទ្រនោះច្រើនណាស់ ទស្សនាពីចម្ងាយទៅឃើញព័ណ បៃតងដូចស្លឹកឈើ ហើយមានឱជារសប្រៃណាស់ ផឹកមិនបានទេ ។ មុនដំបូងគេបញ្ចូលទឹកសមុទ្រទៅក្នុងស្រែតាមប្រឡាយដែលគេជីកកាត់ភ្លឺ លុះទឹកចូលពេញស្រែទាំងអស់ហើយ គេបិទមុខប្រឡាយនោះទៅវិញ ឲ្យទឹកដក់នៅក្នុងស្រែទាំងអស់ ។ កាលបើត្រូវចំហាយក្តៅខ្លាំងមក ទឹកក្នុងស្រែក៏រីងហួតស្ងួតអស់ទៅវិញ កកជាអំបិលដុំធំតូចនៅក្នុងស្រែ អ្នកម្ចាស់ស្រែទៅកើបយកអំបិលនោះមក ហើយលាងដីដែលជាប់នៅនឹងអំបិលនោះឲ្យជ្រះចេញ ប៉ុន្តែគេប្រយ័ត្នមិនឲ្យរលាយអំបិល ។ អំបិលលាងទឹកស្អាតហើយ គេនាំយកទៅលក់គ្រប់តំបន់ ហេតុដូច្នេះបានជាយើងកល់គ្នាមានអំបិល ។

អំបិលមានប្រយោជន៍ធំបំផុត សម្រាប់បង់សម្ល - នំ ចំណីឲ្យមានឱជារសប្រៃ ហើយនឹងប្រឡាក់ត្រី សាច់ទុកឲ្យបានយូរផង និយាយដោយពិតទៅ ចំណីអាហារស្ទើរទាំងពួង បើគ្មានអំបិលយើងបរិភោគពុំបានឡើយ ។

នៅស្រុកខ្មែរគ្មានកន្លែងធ្វើអំបិលធំដុំទេ ពិតមែនតែក្នុងដែនខ្មែរខាង

ទិសនិរតីទល់នឹងស្រមុទ្រ ហើយនៅក្នុងខេត្តនោះមានភូមិមួយឈ្មោះថា ភូមិស្រែអំបិល គេក៏មិនធ្វើអំបិលច្រើនទេ ព្រោះទឹកស្រមុទ្រនៅទីនោះ មានជាតិអំបិលមិនសូវល្មមនឹងកម្លាំងនៀយហត់ ហើយនឹងសោហ៊ុយ បង់វាតផង ។

# កុមារដ្ឋាន

## រៀនពាក្យហាត់ភាសា

### អាទិត្យទី១ · អំពីពេល

ពាក្យ– ព្រឹក, ល្ងាច, ព្រលប់, អធ្រាត្រ. ថ្ងៃ យប់, ថ្ងៃត្រង់, ព្រហាម, ព្រលឹម, ល្ងាចត្រជាក់, ព្រលប់ធំ, យប់ងងឹត, ថ្ងៃក្ដៅ, ភ្លាក់ពីព្រឹក, ទៅពីព្រហាម, មកទាំងព្រលឹម ។

ភាសា– ព្រលឹមឡើងអ្នកធ្វើអ្វីខ្លះ ? វេលាយប់អ្នកធ្វើអ្វីខ្លះ ? ឪពុកម្ដាយអ្នកធ្វើអ្វីវេលាថ្ងៃ ?

### អាទិត្យទី ២ ·– ពេល (ត)

ពាក្យ.– ថ្ងៃនេះ, ថ្ងៃមុន, ម្សិល, ម្សិលម៉្ងៃ, ម្សិលម៉្ងៃមួយនាយ

ស្អែក, ខានស្អែក, ខានស្អែកមួយ ៗ ថ្ងៃក្តៅ, យប់ត្រជាក់, ព្រលប់ល្ហើយ, អធ្រាត្រត្រជាក់ អធ្រាត្រស្ងាត់ ៗ ទៅស្អែក, មកថ្ងៃនេះ ៗ

## អាទិត្យទី៣- ពេល (ត)

ពាក្យ.- អាទិត្យ, ចន្ទ, អង្គារ, ពុធ, ព្រហស្បតិ៍, សុក្រ សៅរ៍, ខែ, កើត, រនោច, ពេញបូណ៌មី-ខែដាច់, ខែមានថ្ងៃ ៣០, ខែមានថ្ងៃ២៩, មួយអាទិត្យ ៗ

ភាសា- ថ្ងៃណាខ្លះអ្នកឈប់ទៅសាលារៀន? ថ្ងៃអ្វីខ្លះអ្នកទៅសាលារៀន? ខែឧសភាមានប៉ុន្មានថ្ងៃ?

## អាទិត្យទី៤- ពេល (ត)

ពាក្យ- ខែ មិគសិរ, បុស្ស, មាឃ, ផល្គុន, ចេត្រ, ពិសាខ ជេស្ឋ, អាសាឍ, ស្រាពណ៍, ភទ្របទ, អស្សុជ, កត្តិក ៗ ស្រែហ្វួត, វាល, លឿន, ស្រូវទំ, ដីរឹង, ដីស្អិត, ស្ទឹកស្រស់, ដីសើម ៗ រាប់ថ្ងៃ, សាបស្រូវ ព្រោះស្រូវ, ភ្ជួរស្រែ; ច្រូតស្រូវ, ដកសំណាប, ទឹករង ៗ

ភាសា- សុំឲ្យគ្រូប្រាប់សិស្ស មិគសិរ ២៩ ថ្ងៃ ៗ បុស្ស៣០ ថ្ងៃ ៗ មាឃ២៩ ថ្ងៃ ផល្គុន៣០ ថ្ងៃ ៗ ចេត្រ២៩ ថ្ងៃ ពិសាខ៣០

ជេស្ឋ ២៩ ថ្ងៃ ៗ អាសាឍ ៣០ ថ្ងៃ ស្រាពណ៍ ២៩ ថ្ងៃ ៗ ភទ្របទ ៣០ ថ្ងៃ ៗ អស្សុជ ២៩ ថ្ងៃ ៗ កត្តិក ៣០ ថ្ងៃ ៗ ចូររាប់ខែទាំង ១២ ៗ អ្នកស្រែតាំងធ្វើអ្វីពីខែជេស្ឋទៅ ? នៅខែមិគសិរអ្នកបានឃើញពណ៌វាលដូចម្ដេច ?

### រៀនមើល

អាទិត្យទី ១ និងទី ២– ពេលវេលា

(សៀវភៅបឋមវិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ ១២៣)

អាទិត្យទី៣ និងទី៤– យប់ . អាទិត្យ ខែ ឆ្នាំ

សៀវភៅដដែល ទំព័រ ១២៤ )

---

## បរិច្ឆណដ្ឋាន

### រៀនពាក្យនិងភាសា

អាទិត្យទី១– ការធ្វើស្ករ

ពាក្យ- ទឹកអំពៅ, ទឹកត្នោត, អំពៅ, ត្នោត, ឃ្នាប, ដំបៀត កាំបិត, បំពង់, បង្អោង, គុក, ខ្ទះ, ពុម្ព, ក្អម, ពាង, ស្រាក់ស្ករ ។

គុណនាម- ផ្អែម, ជូរ, ខាប់, រាវ, ស, ខ្មៅ, លឿង ក្រមាប, ព្រឿង មូល, សំប៉ែត, ស្រួយ, ផ្អាប, ឈ្ងុយក្រអូប ល្អិត, រអិល ។

កិរិយា- សក, គាប, សំរក់, ត្រង, រំងាស់, រិត, បំពង ចាក់ស្ករ, ស្រាក់ស្ករ, បង្ខះ, រលាយ, កក, ។

ភាសា- បង្ហាញស្ករគ្រប់យ៉ាង រួចហើយទើបចោទសួរ ។

រុក្ខជាតិអ្វីខ្លះដែលមានទឹក ឯម ផ្អែម ?

រុក្ខជាតិអ្វីនៅស្រុកខ្មែរដែលឲ្យទឹកផ្អែមច្រើន ? ស្ករមានសណ្ឋានដូចម្តេចខ្លះ ?

## អាទិត្យទី២- ការធ្វើប្រេង

ប្រេងដូង, ប្រេងល្ហុង, ប្រេងសណ្តែក, ប្រេងល្ង, ប្រេងសំពេង, ខាញ់គោ, ខាញ់ជ្រូក ។ ដូង, ល្ហុងខ្វង, ល្ង, សណ្តែកដី, សំពេង ។ ដំរទឹក, ត្រាប, ឈើពាល ។ ដំរពារ, ម្រក្សណ៍, ។

គុណនាម- ល្អិត, ខាប់, រាវ, ស្អិត, ថ្លា ព្រឿង, ខ្មៅ, រលោង, រលីប, ស្រិល ។

កិរិយា— ស្ងោរស្រែង, បំពុយ, បំពៀរ, កូនសង្កត់, ដួស, កោស, បុក, ដងដំរ, ខ្ទិក, ពរ' លាប, អុជ, លំអិល, គ្រឿងបន្ទ្រក, លាបថ្នាំ ឆា, ចៀនអាហារ ។

អាទិត្យទី ៣– អំពីជ្រលក់ ប្រហុក ស្បែក

នាម·— ពណ៌; មក្លឿ; ស្បែង; ស្នាប់; ត្រហូត; ដម្ពូ; ត្រុំ, រមៀត, ខ្ទឹរ ។ ប្រហុក, ម្អក, ផ្សិត, កាពិ, ត្រីបង្កា, ត្រីប្រា រ៉ស់; ផ្កា; ព្រួល; បបែល, កំពិស ព្រាន ។ ស្បែកគោ; ស្បែកក្របី, ស្បែកក្រពើ, ស្បែកថ្មាន់, ស្បែកពស់, ប្រមោយដំរី, ស្បែកខ្លា, ស្បែកឈ្លូស, ស្រើស, ក្ដាន់ ។ ស្បែកសម្ងាប់, ហិបស្បែកជើង, គ្រឿងទឹមសេះ ស្រោម, ស្គរ, កំពល, ពស្ត្រា ។

គុណនាម— ពណ៌ខៀវខ្ចី, លឿង, បៃតង ក្រហម, ដម្ពូ, ស្វាយ ។

ប្រហុកខ្ពោះ, ខុល, ល្អ, ឈ្ងុយ ។ ម្អកផ្អូរ ប្រែ សាប កាពិ ស្អុយ ម៉ដ្ឋ អាក្រក់ ។ ស្បែកជាប់ ស្វិត ក្រាស់ ។ ស្ដើង គគ្រោ គគ្រើម ពន្ទិកពញាក់ ។

កិរិយា=ជ្រលក់ ត្រាំ សំឡាប់ កូរ បុក រ៉ែរាស់ ប្រឡាក់ ហាល វះ ស្រកាវ ពន្ធះ ដេរ កាត់ ចៀរ រាស់ ពាស ទិម ។

អាទិត្យទី ៤–

សុំបង្រៀនពាក្យភាសាពីអាទិត្យមុន ៗ ឡើងវិញ ។

អាទិត្យទី១- រៀនមើល

## ១– ការធ្វើស្ករ

តែស្វាធ្យាយន៍ទំព័រ ១៣៦ ។

ពន្យល់ពាក្យ= ប្រទេសឥណ្ឌូចិន= ដម្បន់មួយមានស្រុកខ្មែរ យួន អណ្ណាម យួនតុងកឹង យួនកូសាំងស៊ីន និងលាវ

ឃ្នាប= ប្រដាប់សម្រាប់គាប ។ ពុម្ព= កង់ធ្វើដោយស្លឹកត្នោតសម្រាប់ចាក់ស្ករឲ្យបានជាស្ករផែន ។

អានពាក្យ= ប្រោះ - ឲ្យអានប្រស់ – អម្បោះ ប្រោះគ្រោះ ។

ពាក្យសួរ– ក្នុងប្រទេសឥណ្ឌូចិនគេធ្វើស្ករនឹងទឹកអ្វី ? គេធ្វើដូចម្ដេច នឹងបានទឹកពីអំពៅ ? ពីត្នោត ? គេយកទឹកត្នោត ឬ ទឹកអំពៅទៅ ធ្វើដូចម្ដេចទៀតទើបបានជាស្ករ ?

## ២– អំបិល

(សៀវភៅដែលទំព័រ១១៤)

កែតម្រូវពាក្យ – ស្រមុច្រ ជា ស្រមុច្រ, ថ្បូង ជា ត្បូង ។ សុំឲ្យ **តែងសេចក្ដីពោទសួរផងចុះ**

អាទិត្យទី២– ត្រឡប់មករកចិញ្ចឹមជីវិតនៅស្រុកស្រែ

(វិជ្ជាខេមរ - បដ - ទំព័រ ៨១ )

ការជ្រលក់សំពត់ (វត្ថុស្វា · បដ. ទំព័រ ១៥២ ដល់ហៅមរ )

ពាក្យប្រើញឹកញយ – អម្បោះ ពណ៌ រមៀត ព្រហូត ខ្នុរ ផ្ទូ៧ ខែ ស្រុត សប្បាយការ

ការជ្រលក់សំពត់ (ត) ដល់ចប់

កែតម្រូវពាក្យ - គ្រីជាគ្រី សរជាស អាច់ជាអាចម៍

អាទិត្យទី៣– ១– ស្លូបត្រី (វិជ្ជាខេមរ. បដ ទំព័រ ៩៣

២ – ធ្វើប្រេងហើយនឹងសាប៊ូ (វត្ថុស្វា - បដ. ទំព័រ ១៣៧)

៣– ការនេសាទត្រីនៅទន្លេសាប (វិជ្ជាខេមរ -បដ- ទំព័រ ៩៥ )

អាទិត្យទី ៤.–

១– ការនេសាទត្រីនៅទន្លេសាប (ត) វិជ្ជាខេមរ. បដ. ទំព័រ៩៧)

២– ការសំឡាប់ស្បែក· (វត្ថុស្វា· –បដ – ទំព័រ១៦៤ )

## តែងសេចក្តី

១– ចូរធ្វើប្រយោគនឹងពាក្យមួយ ៗ ដូចមានខាងក្រោមនេះ ស្ករ

ទឹកត្នោត ទឹកអំពៅ ជើងក្រានឬគុក នំបំណី ស្ករផែន ស្ករពាំ ស្ករស ល្អិត ស្ករសរឹងដុំតូច ៗ ស្ករក្រហមបន្ទះ ។

គំរូធ្វើប្រយោគ– ស្ករជាវត្ថុផ្អែម ។ នៅស្រុកខ្មែរគេធ្វើស្ករនឹងទឹកត្នោត ឯស្រុកឯទៀត ៗ គេធ្វើស្ករនឹងទឹកអំពៅ ។

គេរំងាស់ទឹកត្នោតឬទឹកអំពៅនឹងខ្ទះ ដាំលើជើងក្រានហៅថាគុក ។ ស្ករប្រើការធ្វើនំចំណី ។ នៅស្រុកខ្មែរ គេធ្វើស្ករផែន គេធ្វើស្ករពាំ ដាក់ក្នុងពុត ឬ ក្នុងក្អម ស្ករសល្អិតមកពីស្រុកចិន ឬស្រុកជប៉ុន ។ ស្ករសរឹងដុំតូចៗ មកពីស្រុកបារាំង ។ ស្ករមន្ទះស្តើងពណ៌លឿងធ្វើនៅស្រុកយួន ។

២– ចូរធ្វើតាមលំអាន ពីអាទិត្យមុន -ពីប្រេងល្ហុងខ្មែរ

៣– ចូរដាក់ការឲ្យសិស្សធ្វើប្រយោគម្នាក់ ១ អំពីមកក្បឿ

## សរសេរតាមសូត្រ

សុំឲ្យរើសយករឿងមើលមកធ្វើសរសេរតាមសូត្រ

# អាជិកជ្ជន

## នព្វន្ត

### លេខចែកនឹង ១០-១០០-១០០០

ដើម្បីនឹងចែកចំនួនអ្វីមួយនឹង ១០-១០០-១០០០... នោះគេគ្រាន់តែចំណាំដោយកណ្ដាក់ខាងស្ដាំចំនួននោះ មួយខ្ទង់ចំនួនណាដែលចែកនឹង ១០ ពីរខ្ទង់ចំនួនណាដែលចែកនឹង ១០០... បីខ្ទង់ចំនួនណាដែលចែកនឹង ១០០០

ឧបមា — ១២៥' : ១០ — ១២'៥

១២៥' : ១០០ — ១'២៥

១១២៥' : ១០០០ — ១'១២៥

បើខ្វះលេខនៅខ្ទង់ណាគេដាក់សូន្យបគ្រ្គប់ខ្ទង់នោះ

ឧបមា: ៧' : ១០ — ០'៧

២៥' : ១០០ — ០'២៥

១២៥: ១០០០ — ០'១២៥

វិធីហាត់មាត់ទទេ ចែកចំនួនតាំងអស់នេះ

នឹង ១០០០ – ២៣៥៣៛ ។ ៩០២ម ។ ៧៣.៥១៩ល ។

នឹង ១០០ – ២៤០៛ ។ ៤៩ម ។ ៤១៧៨ល ។

នឹង ១០ – ៧៛ ។ ១០៩ម ។ ៤៣៥ល ។

សៀវភៅមើល ១០០ ថ្លៃ ១២៣៥៛ ។ តើសៀវភៅមើលមួយថ្លៃប៉ុន្មាន ។ ស្រាមួយធុង ១០០០ លីត្រថ្លៃ ១៩៥៣៩៛ ។ តើមួយលីត្រថ្លៃប៉ុន្មាន ។

វិធីហាត់សរសេរ បំណោទ.–

អ្នកលក់សត្វ ទិញស៊ុតមាន់ចំនួន ១០០០ ថ្លៃ ៤២០៛ ។ តើស៊ុតមាន់មួយឡូថ្លៃប៉ុន្មាន ។

អ្នកជំនួញម្នាក់ទិញស្រាទំពាំងបាយជូរ ៥ ធុង បំណុះក្នុងមួយធុង ២០០ លីត្រ ថ្លៃជាប្រាក់ ១២.៥៣០៛ ។ តើក្នុងមួយលីត្រទិញថ្លៃប៉ុន្មាន ។

## លេខចែកបែងភាគគត់

## (លេខតាំងចែកនឹងចំនួនបែងភាគគត់)

ឧបមា: ៦២៣:៤,៥ –

```
៦២៣០ |៤៥
១៧៣  |១៣៨
 ៣៨០
  ២០
```

គេត្រូវធ្វើជើងហារនោះ (៤,៥) ឲ្យទៅជាចំនួនជុំ (៤៥) ដូច្នេះគេត្រូវលុបកណ្ដក់សញ្ញាក្នុងជើងហារនោះហើយគេត្រូវថែមសូន្យនៅលេខតាំង (៦២៣ ឲ្យទៅជា ៦២៣០) តាមចំនួនលេខក្នុងបំណែកថែមភាគជាជើងហារនោះ ៗ

**វិធីហាត់សរសេរ** ចូរធ្វើលេខចែកខាងក្រោមនេះ

៦៤៩: ៥,៤ — , ៨.៧០៤: ៥,៣ —

៤៣៧. ៣,២ — , ២៥៩៣: ៤,៣ —

## បំណោទ –.

គេទិញទាមួយថ្លៃ ១២៛២៥ តើគេទិញបានទាប៉ុន្មានបើគេមានប្រាក់ ៩៨៛ ៗ

សំពត់មួយផាប់មាន ៤៨ ម៉ែ ៣៥ លក់ថ្លៃទាំងអស់ ១៨៣៦៛ ៗ តើមួយម៉ែត្រលក់ថ្លៃប៉ុន្មាន ៗ

**សូមបង្រៀនសិស្សឲ្យធ្វើ** – បំណោទក្នុងលេខទាំងបួនបែបឡើងវិញ

## រង្វាស់រង្វាល់

សាបង្រៀនអំពីរង្វាស់ប្រវែងឡើងវិញ

**វិធីហាត់មាត់ទទេ** ខ្នាតដើមនៃវិធីវាស់ប្រវែងនោះគឺអ្វី ។ ម៉ែត្រមានប៉ុន្មានយ៉ាង ។ ម៉ែត្រគេធ្វើអំពីអ្វីខ្លះ ។ រង្វាស់តូចជាងម៉ែត្រនោះគឺអ្វីខ្លះ ។ ខ្នាតធំជាងម៉ែត្រនោះអ្វីខ្លះ ។

**វិធីហាត់សរសេរ** ឲ្យសរសេរជាម៉ែត្រចំនួនខាងក្រោមនេះ ។

៨ហម ។ ២៣ដាម ។ ២៥សម ។ ៧ហម ។ ៨.០០០មម ។

៨៥៣សម ។ ៤ដម ។

**បំណោទ** .– អ្នកវេញខ្សែម្នាក់វេញខ្សែនៅថ្ងៃច័ន្ទបាន ៣៥ម ថ្ងៃអង្គារបាន ៤ដាម លើសថ្ងៃច័ន្ទ ហើយថ្ងៃពុធបាន ៨ ម៉ែត្រលើសថ្ងៃអង្គារទៀត តើក្នុង ៣ ថ្ងៃនោះ គេវេញខ្សែបានប៉ុន្មានម៉ែត្រ ។

– ពីភ្នំពេញទៅកំពង់ឆ្នាំងមានចម្ងាយ ៨៩គ ម ពីកំពង់ឆ្នាំងទៅពោធិ៍សាត់មានចម្ងាយ ១០០គ ម ។ តើពីភ្នំពេញទៅពោធិ៍សាត់ចម្ងាយប៉ុន្មាន ។

## សាបង្រៀនពីរង្វាល់ចំណុះ

**វិធីហាត់មាត់ទទេ** មួយហិកតូលីត្រមានប៉ុន្មានដេកាលីត្រ ។

មានប៉ុន្មានលីត្រក្នុង ៥ដា.ល ។ ៧ហ.ល ។

កន្លះដេកាលីត្រមានប៉ុន្មានលីត្រ ។

កន្ទះហិកតូលីត្រមានប៉ុន្មានដេកាលីត្រ ។

បង្គៀងមួយស៊ីប្រេងកាតក្នុង ១ ខែ ៦ លីត្រ តើក្នុងមួយឆ្នាំវាស៊ីអស់ប៉ុន្មានលីត្រ ។

- ១ លីត្រមានប៉ុន្មានដេស៊ីលីត្រ ។
- មានប៉ុន្មានមីលីលីត្រ ទើបបាន ១ លីត្រ ។
- មានប៉ុន្មានសង់ទីលីត្រក្នុង ២ លីត្រ ។ ៥ ដេកាលីត្រ ។

បំណោទ ៈ— គេដាក់ទឹកនៅក្នុងថាំងធំមួយ ។ លើកដំបូង ២ ហ,លកន្ទះមួយ លើកបន្ទាប់ ៤ ដា ល.កន្ទះ ហើយលើកក្រោយបំផុត ២៤ ល គេសួរថាបុះគេដាក់ទឹកទៅក្នុងថាំងនោះទាំងអស់ប៉ុន្មាន ។

- ឈ្មួញម្នាក់ទិញស្រា ៣ ធុងចំណុះ ២២៥ លីត្រក្នុង ១ ធុង តើស្រានោះថ្លៃប៉ុន្មានទាំងអស់ បើក្នុង ១ ហិកតូលីត្រថ្លៃ ១៤០៛ ។
- ល្ងមួយដេកាលីត្រថ្លៃ ១៦៛៩០ តើល្ង ១២ ការ៉ុងថ្លៃប៉ុន្មាន បើក្នុងមួយការ៉ុងមានចំណុះ ២ ហ,ល.កន្ទះ ។

# មជ្ឈិមដ្ឋានទី ១

## នព្វន្ត

### លេខចែកចំនួនទសភាគ

**អាទិត្យទី ១.–** *លេខដំណាំងជាចំនួនទសភាគ*

**ឧទាហរណ៍:** *ក) ក្មេង ៨ នាក់បានប្រាក់ ៣៩៛,៤៦ តើក្មេងម្នាក់ៗ ត្រូវបានប៉ុន្មានរៀល ។*

**របៀបពន្យល់:** *ក្នុង ៣៩៛,៤៦ ភាគគត់មានប៉ុន្មាន ? ៣៩៛ ។*

| | | |
|---|---|---|
| ៣៩ ៤៦ | ៨ | ចំនួននេះចែកនឹងគត់ ៨ បានឬទេ ។ |
| ៧ ៤ | ៤,៩៣ | បាន ។ ក្នុង ៣៩ មាន ៨ បួនដង |
| ២៦ | | ៤ ×៨ = ៣២ យកទៅកាត់នឹង |
| ២ | | ៣៩ នៅសល់ ៧ ។ ៧ គត់ចែក |

*នឹង ៨ មិនបានទេ ហេតុនេះដល់កណ្ដក់សញ្ញា ត្រូវដាក់គំនូសនេះនៅចំនួនលទ្ធ គឺខាងស្ដាំលេខ ៤ រួចទំលាក់លេខទសភាគ ៤ ដែលនៅខាងស្ដាំកណ្ដក់សញ្ញា ហើយធ្វើលេខតទៅដូចធម្មតា ។*

សុំរំលឹកសិស្សថា ៖ តែដល់កណ្ដក់សញ្ញា ត្រូវឲ្យដាក់គំនូសសំគាល់ នោះនៅចំនួនល័ព្ធតាម សឹមទំលាក់លេខទសភាគមកទៀត ។

**ការហាត់បញ្ជាក់ ៖** ឲ្យធ្វើឲ្យបានច្រើននៅលើក្ដារខៀន ៦៤,៧៥. ២១ = ២៣៤ស៊ី ៥០ : ១៧ = ; ៥៤៨ គ្រ ៧០ : ២៣ ៩៤២ តក្រ ៤០ : ៧៣ = ៨០៦៧ម ៦០ : ៩៤ = ..... ។

**ការហាត់សរសេរ ៖** ត្រីខ ៧២ ប្រអប់ ទិញមកថ្លៃទាំងអស់ ៥៤៣,៦០ ឈ្មួញបង់បានចំណេញទាំងអស់ ១៦៥,៨៥ តើអ្នកនោះត្រូវលក់ត្រីខ ១ ប្រអប់ថ្លៃប៉ុន្មាន ។

១) មនុស្សម្នាក់ទិញផ្លែក្រូចពោធិ៍សាត់ ៦ ផ្លែសរុប ៥,៧០ តើក្រូច ១ ថ្លៃប៉ុន្មាន ។

**របៀបពន្យល់ ៖** ក្នុង ៥,៧០ ភាគគត់មានប៉ុន្មាន ។ ៥ ។ ចំនួន

| | | |
|---|---|---|
| ៥,៧០ | ៦ | នេះចែកនឹងគត់ ៦ បានឬទេ ។ ទេ ។ |
| ៣០<br>០ | ០,៩៥ | ហេតុនេះត្រូវដាក់សូន្យ ១ នឹងកណ្ដក់ |

សញ្ញានៅចំនួនល័ព្ធ រួចទំលាក់លេខទសភាគនៅខាងស្ដាំកណ្ដក់សញ្ញា ហើយធ្វើលេខតាមធម្មតា ។

**ការហាត់បញ្ឈាក់ៈ** ឲ្យធ្វើលេខនៅលើក្ដារខៀនឲ្យបានច្រើន ៖

២ម ១០៧ · ៤៩ = ៣ល ១៩៦ : ៦៨ = ៤៧គ,ម ៥៩៤ : ៦៥៧ =

៤៩គ,ក ៧៨៥ : ៨០៥ = ។ល។

**ការហាត់សរសេរ** មនុស្សម្នាក់ទិញឈើគូស ១ ហិបមាន ២២៥ ប្រអប់ ថ្លៃសរុប ១៦៥ រៀល គេចេញឈ្នួលលីយកមកផ្ទះអស់ ២រ,៤០ បង់ពន្ធ ១១រ,៧៥ = តើអ្នកនោះត្រូវលក់ឈើគូស ១ ប្រអប់ថ្លៃប៉ុន្មានឲ្យបានចំណេញ ៤៧រ,៤០ ?

**អាទិត្យទី ២.—** លេខដំណាំងនឹងផលហារជាចំនួនទសភាគដូចគ្នា ។

**ឧទាហរណ៍ៈ** ស្រីម្នាក់ទិញទេសឯក ៣ម,៧៥ ថ្លៃតាំងអស់ ៥៤រ,៧៥ តើទេសឯក ១ ម៉ែត្រថ្លៃប៉ុន្មាន ។

**របៀបពន្យល់** លេខដំណាំងមានលេខទសភាគប៉ុន្មានខ្ទង់ ៗ ផលហារមានប៉ុន្មានខ្ទង់ ៗ ២ ៗ ហេតុនេះត្រូវលុបក្បៀសចោលទាំងសងខាង ហើយចែកលេខដូចជាចំនួនគត់នឹងចំនួនគត់ ។

បើមានចំនួនសេសឬអស់លេខដំណាំង ហើយចង់ចែកលេខតទៅ

ទៀត ត្រូវដាក់គណ្ដក់សញ្ញាខាងស្ដាំចំនួនលំដ្ឋ. ហើយថែមសូន្យ ១ នៅខាងស្ដាំចំនួនសេសហើយចែកទៅ ។

សុំរំលឹកសិស្សថា: បើនៅខាងលេខដំណាំង ចំនួនលេខទសភាគតូចជាងចំនួនទសភាគខាងផើងហារត្រូវថែមសូន្យ នៅលេខដំណាំងតាល់តែចំនួននេះមានលេខទសភាគស្មើនឹងផើងហារដូចជា ១៧ម ៣ ៥,១៧= ៣ម ៣៤ ។

បើសិនណាផើងហារមានលេខទសភាគតូចជាងចំនួនទសភាគនៅលេខដំណាំង ត្រូវបង្វិតគណ្ដក់សញ្ញានៅលេខដំណាំងមកខាងស្ដាំ តាមចំនួនទសភាគដែលមាននៅផើងហារ ។

លុះចែកលេខមកដល់គណ្ដក់សញ្ញា ត្រូវដាក់គំនូសនោះនៅចំនួនលំដ្ឋ សំមទំលាក់លេខទសភាគ ហើយចែកលេខតទៅដូចធម្មតា ។

ឧបមា: ៧៣ គ.ក្រ ៧៣៥ : ២ គ.ក្រ ១៤

ការហាត់បញ្ជាក់: ឲ្យធ្វើនៅលើក្ដារខៀនឲ្យបានច្រើន:

៨ល,៤៣ : ៥,៤= ៦រ,៨៤ : ៤,៣= ៧០គ,ម១៨៤ : ៨,៣៦= ។ល។

ការហាត់សរសេរ: កំណាត់សំពត់ ១ គឺប្រវែង៣២ម៥ គេទិញមកថ្លៃ ៨៨៨រ,៨៧ គេលក់ទៅវិញបានទាំងអស់១.០១០រ,៥០ តើគេចំណេញក្នុងមួយម៉ែត្របានប៉ុន្មាន ។

អាទិត្យទី ៣.– អំពីលេខគុណចំនួនអនិយមភាគ :

ឧទាហរណ៍ៈ នៅសាលាកូនសិស្សរៀនក្នុង ១ ថ្ងៃ ៥ម ៣០ ចុះក្នុង ១ អាទិត្យវារៀនប៉ុន្មានម៉ោង បើវាឈប់អស់ ២ ថ្ងៃ ?

របៀបពន្យល់ៈ សួរសិស្សថា: ក្នុង ១ អាទិត្យឯងមករៀនប៉ុន្មានថ្ងៃ ? ៥ថ ? ចុះក្នុង ១ ថ្ងៃឯងរៀនប៉ុន្មានម៉ោង ? ៥ម ៣០ ? បើ ៥ ថ្ងៃវាត្រូវជាម៉ោងដូចម្តេច ? ច្រើនជាង ៥ ដង ? ៥ម ៣០ × ៥ = ២៥ម ១៥០ ម.ន ? គុណមីនុតមួយប៉ែក គុណម៉ោងមួយប៉ែក ៣០មន × ៥ = ១៥០ម.ន ៥ម × ៥ = ២៥ ម៉ោង រួចបំបែកចំនួនមីនុតឲ្យទៅជាម៉ោង ហើយយកចំនួនម៉ោងដែលឃើញនោះទៅបូកនឹងចំនួនម៉ោងដែលគុណទៅឃើញមុននោះគឺថា ១៥០ម.ន = ២ ម៉ោង + ២៥ម = ២៧ ម៉ោង សល់ចំនួនមីនុត គឺ ៣០ មីនុត ទុកឲ្យនៅដដែល ៥ម ៣០មន × ៥ = ២៧ម ៣០ម.ន. ?

ការហាត់បញ្ហាៈ សុំឲ្យធ្វើឲ្យបានច្រើននៅលើក្ដារខៀន

## រង្វាស់-រង្វាល់

អំពីរង្វាស់រង្វាល់ខ្មែរ

## អាទិត្យទី ១.– អំពីរង្វាស់ប្រវែងរបស់ខ្មែរ

របស់ដែលត្រូវយកមកបង្រៀន= សុំយកហត្ថខ្នាតហ្វីន១ម៉ែត្រ បត់១០កំណាត់ ១ ដេកាម៉ែត្រ ១ មកបង្ហាញ ៗ

របៀបពន្យល់= ក) ខ្នាតប្រធាននៃប្រវែងរបស់ខ្មែរ គឺហត្ថខ្នាតហ្វីន (បង្ហាញឲ្យមើល) ឲ្យសិស្សយកហត្ថនេះទៅផ្ទឹមនឹងម៉ែត្រ ៗ ហត្ថនឹងម៉ែត្រខុសគ្នាដូចម្ដេច ៗ ហត្ថប្រវែងពាក់កណ្ដាលម៉ែត្រ ៗ ហេតុ-នេះហត្ថមានប្រវែងប៉ុន្មាន ៗ (០,ម៥០) ៗ ១ម៉ែត្រមានប៉ុន្មានហត្ថ ៗ ៤ ហត្ថប្រវែងប៉ុន្មាន ៗ ១,ម៥០ ត្រូវជាប៉ុន្មានហត្ថ ៗ

ការហាត់ឲ្យចេះប្រើប្រាស់= ចូរឯងស្មានមើលប្រវែងបណ្ដោយនឹងទទឹងក្ដារខៀនធំនេះ តើមានប៉ុន្មានហត្ថ ៗ រួចឲ្យយកហត្ថវាស់បញ្ជាក់មើល ៗ កំពស់ទ្វារមានប្រវែងប៉ុន្មានហត្ថ ៗ សុំឲ្យធ្វើកិច្ចការនេះឲ្យបានច្រើន ៗ

ខ) ខ្នាតខ្មែរដែលវែងជាងហត្ថ = ខ្នាតដែលវែងជាងហត្ថ គឺព្យាម ១ ព្យាមត្រូវជា ៤ ហត្ថ មានប្រវែង ២ ម៉ែត្រ សិន ១ សិនត្រូវជា ២០-ព្យាម មានប្រវែង ៤០ ម៉ែត្រ ៗ

គ) ខ្នាតខ្មែរដែលខ្លីជាងខ្នាតប្រធាន=ខ្នាតដែលខ្លីជាងហត្ថ គឺចំអាម

១ បំណាមប្រវែង ១២ ធ្នាប់ ត្រូវជា ០,ម ២៥ ១ ធ្នាប់ប្រវែង ០,ម ០២១ ។

ការហាត់ឲ្យចេះប្រើប្រាស់= សុំឲ្យសិស្សស្មានប្រវែងបណ្ដោយ ទទឹង កន្លែងរៀន ទ្វារ សួនច្បារ រួចឲ្យយកម៉ែត្រ ឬ ដេកាម៉ែត្រវាស់បញ្ជាក់មើល ហើយឲ្យគិតទៅជាហត្ថ ព្យាម សិន តាមដែលវាស់ទៅឃើញ ។

បើខ្នាតខ្លីវិញ ឲ្យស្មានប្រវែងបណ្ដោយ ទទឹងសៀវភៅ បន្ទះក្ដារក្រាលកម្រាស់មេក្ដារខ្នួន រួចឲ្យគិតទៅជាហត្ថ ជាធ្នាប់ ជាបំណាម ។ល។

ការហាត់ដោយបញ្ជាក់= ២សិនមានប៉ុន្មានព្យាម ។ ប៉ុន្មានហត្ថ ប៉ុន្មានម៉ែត្រ ។ ២៧០ ម៉ែត្រត្រូវជាប៉ុន្មានហត្ថ ។ ប៉ុន្មានព្យាម ប៉ុន្មានសិន ១ម៉ែត្រមានប៉ុន្មានបំណាម ។ ១៣០បំណាមត្រូវជាប៉ុន្មានហត្ថ ។ ប៉ុន្មានម៉ែត្រ ។ល។

កាហាត់សរសេរ = មនុស្សម្នាក់ទិញផាឌិប ៧៤ ហត្ថ ១៩ បំណាម ថ្លៃក្នុង ១ ម៉ែត្រ ១៤រ ៣៩ តើអ្នកនោះចំណាយអស់ប៉ុន្មាន ។

## អាទិត្យទី ២.- អំពីរង្វាល់ខ្មែរ

របស់ដែលត្រូវយកមកបង្រៀន = សុំឲ្យរកតៅ ១ កន្ដាំង ២ .

មួយតៅ កន្ទាំង ៣ មួយតៅ លីត្រឈើទំងអង្ករ ៤ ឬ ៥ ល្អី ថាំងសំរាប់វាល់ស្រូវ ៗ

របៀបពន្យល់ = រង្វាល់ប្រធានរបស់ខ្មែរគឺតៅ ៗ តៅមានចំណុះប៉ុន្មាន ៗ ឲ្យយកលីត្រវាល់អង្ករចាក់ទៅក្នុងតៅ១៥លីត្រ ៗ ប្រយោជន៍នៃតៅ ( ឲ្យសួរសិស្ស ) វាល់ស្រូវ អង្ករ ពោត សណ្តែក ល្ង ៗល ៗ

រង្វាល់ដែលធំជាងរង្វាល់ប្រធាន = រង្វាល់ដែលធំជាងតៅគឺថាំងចំណុះ ២ តៅហៅថាថាំង ៗ

រង្វាល់តូចជាងរង្វាល់ប្រធាន= កន្ទាំង ឲ្យសិស្សយកកន្ទាំង២ ឬកន្ទាំង ៣ វាល់អង្ករចាក់ទៅក្នុងតៅ ហើយសួរថា ១ តៅចំណុះប៉ុន្មានកន្ទាំង មួយកន្ទាំង ២ ត្រូវជាប៉ុន្មានលិត្រ ៗ មួយកន្ទាំង ៣ ៗ

ការហាត់ឲ្យចេះប្រើប្រាស់= ឲ្យសិស្សស្មានគំនរអង្ករ ជាថាំង ជាតៅ ជាកន្ទាំង ហើយវាល់បញ្ជាក់មើល រួចគិតទៅជាលិត្រ ៗ

ការហាត់គិតដោយបញ្ជាក់= ៤ ថាំងមានប៉ុន្មានតៅ ត្រូវជាប៉ុន្មានកន្ទាំង២ សរុបត្រូវជាប៉ុន្មានលីត្រ ៗ ២៤ កន្ទាំង ៤ ត្រូវជាប៉ុន្មានតៅប៉ុន្មានថាំង ៗ ២៤០ លីត្រត្រូវជាប៉ុន្មានតៅ ៗ ប៉ុន្មានថាំង ៗ ប៉ុន្មានកន្ទាំង ៣ ៗ

ការហាត់សរសេរ= អ្នកស្រែម្នាក់ទិញស្រូវ ៣៩០ ថាំង ។ ថ្លៃក្នុង ១ តៅ ២៥៛៥០ អ្នកនោះជួលគេដឹកអស់ ៦៨៛៥០ គិតទៅស្រូវ ១ ថាំងត្រូវជាថ្លៃប៉ុន្មាន ។

## អាទិត្យទី ៣ .— អំពីទម្ងន់របស់ខ្មែរ

របស់ដែលត្រូវយកមកបង្រៀន= ជញ្ជីងគ្រាប់ខ្មែរ ជញ្ជីងចាំងមានថាសព្យួរពីរ កូនទម្ងន់ ២០០ ក្រាម ១០០ ក្រាម ៥០ ក្រាម ២០ ក្រាម ១០ ក្រាម ៥ ក្រាម ២ ក្រាម ១ ក្រាម ១០ ដេស៊ីក្រាម ២ ដេស៊ីក្រាម ៥ ដេស៊ីក្រាម ១ សង្ទីក្រាម ២ សង្ទីក្រាម ៥ សង្ទីក្រាម ១ មីលីក្រាម ២ មីលីក្រាម ៥ មីលីក្រាម ។

របៀបពន្យល់= ទម្ងន់ខ្មែរជាប្រធាន គឺ ដម្លឹង ១ ដម្លឹងទម្ងន់ ៣៧ ក្រ, ៥០

ទម្ងន់ដែលធ្ងន់ជាងដម្លឹង= នាលិ ១ នាលិទម្ងន់ ១៦ ដម្លឹងត្រូវជា ១០០ក្រាម ចុង-១ ចុងទម្ងន់ ៥០ នាលិត្រូវជា ៣០០ គីឡូក្រាម ។ ហាប- ១ ហាបទម្ងន់ ២ ចុងត្រូវជា ៧០ គីឡូក្រាម ។

ទម្ងន់ដែលស្រាលជាងដម្លឹង= ជី ១ ជីស្រាលជាងដម្លឹង ១០ ដងទម្ងន់ ៣ ក្រ ៧៥ ។ ហ៊ុន—១ ហ៊ុនស្រាលជាងជី ១០ ដងទម្ងន់ ០ ក្រ

៣៧៥ ។ លី-១លីស្រាលជាងហ៊ុន ១០ ដងទម្ងន់ ០ក្រ, ០៣៧៥ ។

ការហាត់ឲ្យចេះប្រើប្រាស់= ឲ្យសិស្សស្ទាបវត្ថុផ្សេងៗហើយឲ្យថ្លឹងបញ្ជាក់ រួចឲ្យគិតតាមទម្ងន់ម៉ាំងស្រ ។

ការហាត់គិតដោយបញ្ញា= សុំឲ្យសិស្សធ្វើឲ្យបានច្រើននៅលើក្ដារខៀន ។

## ធរណីមាណសាស្ត្រ

អាទិត្យទី ១.- អំពីកាត់ធ្វើត្រីកោណ

អំពីវ័ណ្ឌមណ្ឌលធ្វើរង្វង់ ការគូរផែនទី

អំពីកាត់ក្រដាសធ្វើត្រីកោណ

ប្រដាប់ប្រដាដែលត្រូវយកធ្វើការ= កន្ត្រៃ កាំបិតបត់ ក្រដាសក្រាស់ ម្ភក្រដាសពណ៌ ឌូប៉ឺដេស៊ីម៉ែត្រ

របៀបបង្រៀន= បង្គាប់ឲ្យកាត់ក្រដាសធ្វើជាត្រីកោណគ្រប់យ៉ាង ត្រីកោណស្មើជ្រុង ត្រីកោណស្មើជ្រុងតាំងពី ត្រីកោណស្មើជ្រុងតែពីរ ត្រីកោណឥតស្មើជ្រុង ។

ត្រូវប្រាប់បញ្ជាក់ថា ត្រីកោណនីមួយ ៗ ត្រូវមានជ្រុងយ៉ាងខ្លីណាស់ ត្រឹមប្រវែង ០,ម ០៨

## អាទិត្យទី ២.– អំពីវណ្ណមណ្ឌល




របស់ដែលត្រូវយកមកបង្រៀន

ពពាយសំរាប់គូរវង្វង់

របៀបពន្យល់ គូរវណ្ណមណ្ឌល នៅលើក្ដារឆ្ពន គូរកន្លែងសំគាល់ ស្នូល រួចឲ្យសិស្សវាស់ប្រវែងពី ស្នូលទៅកណ្ដាប់វង្វង់នេះឲ្យគ្រប់តំបន់ ហើយសួរវាថា ឯងវាស់ទៅឃើញ ដូចម្ដេច ៗ ប្រវែងស្មើគ្នាទាំងអស់ ៗ ឲ្យរកន័យ

វណ្ណមណ្ឌលគឺវង្វង់មូលមួយ ដែលប្រវែងពីស្នូលគ្រប់តំបន់វង្វង់ស្មើគ្នាទាំងអស់ ៗ

**អំពីបន្ទាត់ពុះ** គូសនៅនាវណ្ណមណ្ឌលឲ្យមើល ហើយសួរថា: បន្ទាត់ពុះផ្ដោះពីណាទៅណា ៗ កាត់តាមណា ៗ ឲ្យរកន័យ ៗ បន្ទាត់ពុះជាបន្ទាត់ត្រង់មួយ ផ្ដោះពីកណ្ដាប់វង្វង់ម្ខាងទៅម្ខាងកាត់តាមស្នូល

កាំ គូសនៅនាវង់មណ្ឌលឲ្យមើលហើយសួរថា: បន្ទាត់នេះឆ្ពោះពីណាទៅណា ៗ ចេញពីស្នូលទៅកាន់កណ្ដាប់វង្វង់ ៗ ឲ្យគេន័យ ៗ

ការរំលឹកដោយពិនិត្យ= កាំស្មើនឹងអ្វី បន្ទាត់ពុះមួយស្មើនឹងអ្វី

ការគិតគួររកប្រវែងវង្វង់មណ្ឌល = ឧបមា = វង់មណ្ឌលមួយមានបន្ទាត់ពុះប្រវែង ៤ ម៉ែត្រ តើវង់មណ្ឌលនោះប្រវែងប៉ុន្មាន ៗ

របៀបគិតគួរធ្វើលេខ= ត្រូវយកបន្ទាត់ពុះទៅគុណនឹងមេ ៗ នោះមានគំនូសសំគាល់ π អានថាពី ៗ នេះមានតម្លៃ ៣.១៤១៦ (π ៣,១៤១៦) បន្ទាត់ពុះ ៤ម៉ × π = ៣,១៤១៧ = ១២ម ៥៦៦៤

អក្សរសញ្ញា= វង់មណ្ឌល (វ.ម. = ប.ព. × π)

ការហាត់បញ្ជាក់ = ឲ្យធ្វើលើក្ដារខ្មៀនឲ្យបានច្រើន

កង់មួយមានបន្ទាត់ពុះប្រវែង ១,ម៥០ តើជុំវិញកង់នោះប្រវែងប៉ុន្មាន ៗ មាត់អណ្ដូងទឹកមួយបន្ទាត់ពុះប្រវែង ២,ម៣៥ តើជុំវិញមាត់អណ្ដូងនោះប្រវែងប៉ុន្មាន ៗ តុមូលមួយកាំប្រវែង ០,៧០ តើមនុស្សប៉ុន្មាននាក់អង្គុយជុំវិញតុនោះបាន បើមនុស្សទាំងនោះអង្គុយឃ្លាតចម្ងាយ ០,ម៣៥

ការបាត់សរសេរៈ ទោចក្រយានមួយកង់មានកាំប្រវែង០,$^{ម}$ ៣៥ តើយាននេះរត់បានចម្ងាយប៉ុន្មាន បើកង់វាវិល ៧៥០០០ ជុំ ។

## អាទិត្យទី ៣.– អំពីផ្ទៃមូល

របស់ដែលយកមកបង្រៀន. ពពាយសំរាប់គូររង្វង់ ម៉ែត្របត់

របៀបពន្យល់.– គូររង្វង់មួយនៅលើក្ដារខ្នួនគួសបំណាំស្នូលឲ្យសិស្សយកម៉ែត្រវាស់កាំ ហើយប្រាប់វាថា ផ្ទៃមូល គឺទីកន្លែងដែលនៅពេញក្នុងរង្វង់នោះ




ការគិតគូររកផ្ទៃមូល យកកាំទៅគុណនឹងកាំ ហើយយកផលទៅគុណនឹងពី ( π )

ឧបមា= តុមូលមួយកាំប្រវែង ០,$^{ម}$ ៧២ តើគេត្រូវទិញសំពត់ទំហំប៉ុន្មានមកធ្វើកំរាលឲ្យពេញតុនោះ

កាំ ០,$^{ម}$ ៧២ × កាំ ០,$^{ម}$ ៧២ = ០,$^{ម}$ ៥១៨៤ × π ៣,១៤១៦ = ១$^{ម}$២ ៦២៨៦០៥

អក្សរសញ្ញា ផ្ទៃ = ផ = ( ក × ក ) × π ឬ π (ពីរយេការេ )

ការហាត់បញ្ជាក់= សុំឲ្យធ្វើឲ្យបានច្រើននៅលើក្ដាឆ្នួន

ស្ពាន់មួយបន្ទះរាងមូល កាំប្រវែង ១ម ៥០ តើផ្ទៃស្ពាន់នោះទំហំប៉ុន្មាន

កំរាលតុមួយបន្ទាត់ពុះប្រវែង ២ម ៨៤ តើកំរាលតុនោះទំហំប៉ុន្មាន ។ គេទិញឈើយកមកធ្វើគំរបមាត់អណ្តូង បន្ទាត់ពុះប្រវែង៣ម ៨៨ តើគំរបមាត់អណ្តូងទំហំប៉ុន្មាន ។

ការហាត់សរសេរ គេទិញស្ពាន់មួយបន្ទះយកមកធ្វើថាស កាំវាទំហំ០ម ៣៥ តើថាសនោះថ្លៃប៉ុន្មាន បើស្ពាន់ ១ ម៉ែត្រក្រឡាថ្លៃ ១២៛ ៥០ ហើយជាងយកឈ្នួល២៣៛៥០ ។

---

## កុមារដ្ឋាន

### នព្វន្ត

សាបង្រៀន ចំនួនដែលរៀន ពីដើមឆ្នាំមក គឺចំនួនដល់ ១០០ លេខបូក លេខសងមានត្រាទុក - គុណចំនួននឹង ២– ចែកចំនួនជា ២ ។

មេរៀនទី១.– សាបញ្ជាក់អំពីចំនួន ពី១ដល់ ១០០

របស់សំរាប់បង្រៀន.– ចង្កឹះបាច់-ចង្កឹះរាយ លុយសេន ប្រាក់កាក់ ១០ សេន ។

របៀបបង្រៀន.–

១-ការរៀនរាប់ចំនួន-ឲ្យសិស្សរាប់របស់បន្ថែមមួយៗពីរៗបីៗ បួនៗ ពី១ដល់ ១០០–រាប់បន្ថយពី១០០មក១វិញ ។

២– រៀនផ្សំចំនួន – ឲ្យសិស្សផ្សំចំនួន ១៥-២៣·៣៧·៤៦-៥៩-៦៥-៧១-៨៧-៩៩ នឹងចង្កឹះបាច់នឹងចង្កឹះរាយ ឬនឹងប្រាក់កាក់នឹងលុយសេន ។

៣– ការរៀនអានចំនួន–ឲ្យសិស្សអានចំនួនដែលសរសេរទុកនៅលើក្ដារខៀនបញ្ជរ ហើយសួរសាកបញ្ចាក់អំពីខ្ទង់នៃលេខ – គ្រូបង្អុលចំនួនឲ្យសិស្សថា · គ្រូថាឲ្យសិស្សបង្អុល ឬឲ្យសិស្សម្នាក់បង្អុលឲ្យសិស្សឯទៀតថាឲ្យសិស្សម្នាក់ទៀតថាឲ្យសិស្សឯទៀតបង្អុល ។

៤– ការហាត់សរសេរចំនួន - គ្រូថាចំនួនឲ្យសិស្សសរសេរនៅលើក្ដារឆ្នួន

៥–ការហាត់មាត់ទទេ.–

៦–ការហាត់សរសេរនៅក្នុងសៀវភៅ

សូមតែងការហាត់ទាំងពីរមុខនេះដាក់ឲ្យសិស្សធ្វើផង ៗ

## មេរៀនទី ២.–ចំនួនដល់១០០

រៀនធ្វើលេខបូកមានត្រាទុក

របៀបបង្រៀន–

១.–មតិសំខ្យា - ឲ្យសិស្សរាប់បន្ថែម ២-៣-៤ ពី ១ ដល់ ១០០ ៗ

២ -ពន្យល់របៀបធ្វើលេខបូកមានត្រាទុក (សិស្សម្នាក់កាន់បង្កើះ ៣៥ សិស្សម្នាក់ទៀតកាន់បង្កើះ ២៧ តើសិស្សទាំងពីរនាក់មានបង្កើះប៉ុន្មាន) គ្រូធ្វើលេខបូក ៣៥+ ២៧ នេះនៅលើក្ដារខៀនជាមួយសិស្សថា៖ ៥ នឹង ៧ ត្រូវជា ១២ ខ្ញុំសរសេរចំនួនពាយ ២ ខ្ញុំត្រាចំនួន ១ នៅខ្ទង់ដប់ ទុកមើម្បីនឹងយកទៅបន្ថែមនឹងខ្ទង់ដប់ ខ្ញុំថា ១ នឹង ៣ ត្រូវជាបួន ៤ នឹង ២ ត្រូវជា ៦ ខ្ញុំសរសេរចំនួនដប់នេះនៅក្រោមចំនួនដប់ឃើញ ៦២ ៗ

៣ - ការហាត់បញ្ជាក់នៅលើក្ដារខៀន៖ ១៦ ២៩ = ៗ

៣៩ + ២៤= ៗ ៤៧ + ២៣= ៗ ៥៤ + ២៨= ៗ

៤– ការហាត់បញ្ជាក់នៅលើក្ដារឆ្នួន៖ ២៣ + ៣៩= ៗ

១៧ + ៤៦= ៗ ៣៥ + ៤៨= ៗ ២៤ + ៤៩= ៗ

៥– ការហាត់សរសេរនៅក្នុងសៀវភៅ

(សូមតែងការហាត់ឲ្យសិស្សធ្វើនៅក្នុងសៀវភៅផង)

មេរៀនទី ៣.- ចំនួនដល់ ១០០

រៀនធ្វើលេខសងមានត្រាទុក ។

មេរៀនទី៤- រៀនគុណចំនួននឹង ៤

មេរៀនទី៥ រៀនចែកចំនួនជា ៤

សូមមើលតាមរបៀបតែងក្នុងទស្សនាវដ្ដីឆ្នាំទី២ លេខ១៨ ទំព័រទី ២៥ ២៦-២៧ និង ២៨ ។

### រង្វាស់រង្វាល់

ក្នុងខែនេះត្រូវសាបង្រៀនមុំពីវិជ្ជាដែលបានបង្រៀនតាំងពីដើមមក សូមរើសវិជ្ជាដែលបានបង្រៀនរួចហើយនោះយកមកបង្រៀន ឬ ពន្យល់ថែមទៀតត្រង់កន្លែងដែលពិនិត្យឃើញថាសិស្សពុំទាន់យល់ច្បាស់ ។ សូមមើលតាមទស្សនាវដ្ដីខែមុន ៗ មានសព្វគ្រប់ស្រាប់ហើយ ។

## បរិច្ឆណដ្ឋាន

### នព្វន្ត

ក្នុងខែនេះត្រូវសាបង្រៀនរបៀបធ្វើលេខ ចំនួនដុំតាំងបួន

បែបនឹងបង្រៀន គុណ ចែកចំនួនបែងភាគនឹង ១០ នឹង ១០០ ។

## មេរៀនទី១.– សាបញ្ជាក់អំពីលេខបូកនឹងលេខសងចំនួនជុំ

## របៀបបង្រៀន.–

១.– ការហាត់គិតដោយប្រាជ្ញា – រៀនបន្ថែម ៥, ៦, ៧, ៨, ៩, ៈ លើចំនួនមួយ – រៀនបន្ថយ ៥, ៦, ៧, ៨, ៩, ពីចំនួនមួយដូចជាៈ ៣៧៛ + ៥៛ : ។ នាំសិស្សថាៈ ៧ នឹង ៥ ត្រូវជា ១២ ។ ៣០ នឹង ១២ ត្រូវជា ៤២ ។ ៩៣៛ - ៧៛ = នាំសិស្សរៀនគិតថាៈ ៩០ ដក ៧ នៅសល់ ៨៣ ។ ៨៣ នឹង ៣ ត្រូវជា ៨៦ ។ នាំសិស្សហាត់គិតបែបខាងលើនេះឲ្យបានច្រើនបំផុត ។

២ ការបញ្ជាក់អំពីលេខបូកនឹងលេខសង

ក– អាវ១ថ្លៃ ១៣៥៛ ខោ១ថ្លៃ ៨៧៛ ។ តើខោនឹងអាវត្រូវជាថ្លៃប៉ុន្មាន ?

ខ- គោនឹងសេះ ថ្លៃ ៧៥២៛ បើគោថ្លៃ ៣៥៧៛ តើសេះនោះត្រូវជាថ្លៃប៉ុន្មាន ។

ឲ្យសិស្សធ្វើលេខបូក.លេខសងខាងលើនេះ នៅលើក្ដារខៀន ហើយពន្យល់បន្ថែមត្រង់កន្លែងណា ដែលពិនិត្យឃើញថាសិស្សពុំទាន់យល់ច្បាស់ ។

៣-ការហាត់បញ្ជាក់នៅលើគ្នាផ្ទួន

៤៤៧រ+៣៥៩រៈ ។ ១៧៩រ+៤៥៦រៈ

៥៣៧រ−១៤៥រ ។ ៧៥៣រ−២៤៧រៈ

៤-ការហាត់សរសេរនៅក្នុងសៀវភៅ-

ចូរធ្វើលេខខាងក្រោមនេះ៖

១៦៥រ+៣៥៣រៈ

២៤៦រ+១៧៤រៈ

៥២៧រ+២៤៣រៈ

៤៨១រ+១៥៧រៈ

១-ចំណោទ ឪពុកខ្ញុំគាត់លក់គោ ១ បានប្រាក់ ៣៥៧រ លក់ក្របី ១ បានប្រាក់២៧៣រ ហើយគាត់យកប្រាក់នោះទៅទិញសេះមួយថ្លៃ ៤៧៥រ ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មានរៀលទៀត? ។

មេរៀនទី ២ - សាបញ្ជាក់អំពីលេខគុណនឹងលេខចែកចំនួនជុំនឹងចំនួនមានលេខតែមួយតួ ។ សូមធ្វើតាមរបៀបខាងលើនេះ ហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

មេរៀនទី ៣ - សាបញ្ជាក់អំពីលេខបូក.សង.គុណ.ចែកចំនួនចែងភាគគត់ ។

សូមធ្វើតាមរបៀបខាងលើនេះឲ្យសព្វគ្រប់ផងចុះ ។

## មេរៀនទី ៤ – រៀនគុណចំនួនបែងភាគនឹង ១០ នឹង ១០០ ។

### របៀបបង្រៀន–

–ការហាត់គិតដោយប្រាជ្ញា

១៥រ×១០: ។ ៧រ×១០០: ។ ៤៧រ×១០: ។

៧រ ×១០០:។៥៩រ×១០ : ។ ៩រ ×១០០ ។

២–រៀនគុណចំនួនបែងភាគទឹង ១០នឹង១០០ ។

ធ្វើលេខឬឲ្យសិស្សធ្វើលេខនេះនៅលើក្ដារខៀន ៖

| | |
|---|---|
| ២រ ៥៣ | ៥ម ១៥៧ |
| +១០ | +១០០ |
| ២៥រ ៣០ | ៥១៥ម ៧០០ |

នាំសិស្សពិនិត្យមើលចំនួន ២រ៥៣ នឹង ២៥រ ៣ ។

៥ម ១៥៧ នឹង ៥១៥ម ៧ តើកណ្ដក់សញ្ញាខំទៅខាងណា ចំនួនប៉ុន្មានខ្ទង់? ។

៣– ការហាត់បញ្ចូលនៅលើក្ដារធ្មួន

៥រ,៤៧ × ១០= ។ ៧ម,៣៥៦×១០០= ។

២ម,៥៧២×១០= ។ ១៩ម,១៥០×១០០= ។

៤– ការហាត់សរសេរនៅក្នុងសៀវភៅ.–

ក– ចូរធ្វើលេខខាងក្រោមនេះ៖

៤៛,៧៩×១០=... ។ ៩ម,៤៦៨×១០០=....។

១៧៛,៥០×១០=... ។ ៧៛,៧៤×១០០....។

ខ– ចំណោទ.– ម្ដាយខ្ញុំគាត់មានប្រាក់ ៣៧០៛ គាត់ទៅផ្សារទិញសំពត់១០ម ថ្លៃ៩៛,៤៣ក្នុង១ម ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មាន? ។

មេរៀនទី៥.= បែកចំនួនបែងភាគទី១០ទី១០០

សូមធ្វើតាមរបៀបគុណលេខចំនួនបែងភាគទី១០ទី១០០ខាងលើនេះ ហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

មេរៀនទី៦.– សាបង្រៀនឡើងវិញ

សាបង្រៀនអំពីការដែលបានបង្រៀនក្នុងខែនេះ សូមមើលតាមរបៀបរៀបចំបង្រៀនខាងលើស្រាប់ ។

## រង្វាស់ . រង្វាល់

មេរៀនទី១.– អំពីកូនទម្ងន់មួយគីឡូក្រាម

របស់សំរាប់បង្រៀន.– កូនទម្ងន់ ១ គក្រ– ២ គក្រ–របស់ដែលមានទម្ងន់ ១ គក្រ ២ គក្រ ៣ គក្រ ៥ គក្រ ។

របៀបបង្រៀន.— ១ គ្រូបង្ហាញកូនទម្ងន់ ១ គក្រ—ថាឈ្មោះទម្ងន់នោះឲ្យសិស្សស្ដាប់ហើយសរសេរជាអក្សរ នឹងជាអក្សរកាត់នៅលើក្ដារខៀនឲ្យសិស្សមើល ហើយនាំសិស្សពិនិត្យមើលកូនទម្ងន់នោះរូបពណ៌-ជាតិ អក្សរដែលមាននៅលើកូនទម្ងន់នោះ— កង់ដែលសំរាប់កាន់យកទឹងប្រហោងខាងបាត

២ នាំសិស្សពិនិត្យទម្ងន់ ១ គក្រ—ដោយលើកស្ទានមើលឲ្យបានច្រើនគ្នាបំផុតឲ្យបានស្គាល់ទម្ងន់ ១ គក្រឲ្យច្បាស់ ។

៣— ការហាត់ស្ទានទម្ងន់ ឲ្យសិស្សស្ទានទម្ងន់របស់អ្វីមួយដែលលោកគ្រូដឹងច្បាស់ថាមានទម្ងន់ ១ គក្រ ហើយឲ្យស្ទានទម្ងន់របស់ឯទៀតដែលមានទម្ងន់ ២ គក្រ – ៣ គក្រ

៤– ការហាត់បញ្ជាក់.— មាន ១០ ទម្ងន់ ២០ គក្រ តើមាន ១ – ទម្ងន់ប៉ុន្មាន? មាន ៥ ទម្ងន់ប៉ុន្មាន ?

ស្ករ ១ គក្រថ្លៃ ៥៛ បើគេមានប្រាក់ ២០៛ គេទិញបានស្ករប៉ុន្មានគក្រ ?

៥— ការហាត់សរសេរនៅក្នុងសៀវភៅ

បំណោទ.— ម្ដាយខ្ញុំគាត់មានប្រាក់ ១២០៛ គាត់ទិញសំពត់ ១០ម ថ្លៃ ៨៛៥០ ក្នុង ១ ម សល់ប៉ុំពីនោះគាត់ទិញស្ករសថ្លៃ ៥៛ ក្នុង ១ គក្រ ។ តើគាត់ត្រូវបានស្ករប៉ុន្មានគក្រ ?

មេរៀនទី ២.– កូនទម្ងន់គីឡូក្រាមនិងជញ្ជីង-ការរៀនថ្លឹង ។

ត្រូវមានជញ្ជីង-កូនទម្ងន់ ១ គក្រ–២ គក្រ–៥ គក្រនិងរបស់សំរាប់ថ្លឹង ។

សូមធ្វើតាមរបៀបខាងលើនេះ ប៉ុន្តែសូមបង្ខិលសិស្សឲ្យរៀនថ្លឹងរបស់ឲ្យបានច្រើនផង ។

មេរៀនទី ៣.– អំពីគីឡូម៉ែត្រ ។

រង្វាស់នេះគ្មានវត្ថុជាប្រធានទេ មានតែឈ្មោះគ្រាន់តែសំគាល់ឲ្យដឹងថា ១០០០ ម ឬ ១០០ដាម ឬ ១០ ហ.ម ត្រូវជា ១ គីឡូម៉ែត្រ ។ រង្វាស់នេះគេសំរាប់វាស់ព្រំប្រទល់នគរ–វាស់បណ្ដោយផ្លូវថ្នល់ជាដើម ។

មេរៀនទី ៤.– អំពីការរៀនស្ទានចម្ងាយជាគីឡូម៉ែត្រ ។

នាំសិស្សរៀនស្ទានចម្ងាយពីសាលារៀនទៅកន្លែងមួយ ដែលមានចម្ងាយ ៣, ៤, ៥ គ.ម ។ ចម្ងាយពីកន្លែងមួយទៅកន្លែងមួយទៀត ដែលគេមានកត់សំគាល់នៅគោលតាមផ្លូវថ្នល់ ។

សូមតែងការហាត់សព្វគ្រប់តាមរបៀបខាងលើនេះឲ្យស្រួលផង ។

មជ្ឈមដ្ឋានទី ១

## វត្ថុរសាយន៍

### អាទិត្យទី ១.– ដីស

គោលសេចក្តី.–

១– លក្ខណៈនៃដីស.– ជាវត្ថុរឹងពណ៌ស, គ្មានក្លិនគ្មានរសជាតិ, ផុយ, គេកិនកំទេចជាផង់បានដោយងាយហើយជក់ទឹក ។

២– ដីសនឹងទឹកខ្មេះ– កាលណាគេដាក់ដីសមួយដុំទៅក្នុងទឹកខ្មេះគេឃើញមានពពុះចេញមកហើយ ដីសក៏រលាយបេះចេញជាកំទេច ។

៣– ដីសនឹងកំដៅភ្លើង - កាលណាគេដុតដីសចំនួន ១៥ឬ ២០ នាទី រួចគេយកទៅដាក់ក្នុងទឹកខ្មេះគេពុំឃើញមានពពុះដូចមុនទៀតឡើយ ។ ម្យ៉ាងទៀតគេយកដីសនោះទៅសរសេរពុំជិតឡើយ ពីព្រោះដីសទៅជាកំបោររស់ ។

៤– ថ្មកំបោរ– ដីសមាននៅក្នុងដី៖ គឺជាសិលាជាតិ ។

មានសិលាដទៃទៀតដែលបង្កើតជាពពុះ កាលណាគេចាក់ទឹកខ្មេះ

ទៅលើហើយកើតជាកំបោររស់ កាលណាគេដុតដូចជាដីសដែរគឺថ្មកែវ មនោសិលាជាដើម ។

៥– ប្រយោជន៍ថ្មកំបោរ– ធ្វើជាកំបោរហៅថាកំបោរថ្ម គេធ្វើរូបផ្សេងៗឬភាជន៍ដោយថ្មកែវ ។

## អាទិត្យទី ២–. ដីឥដ្ឋ

មេរៀនសង្ខេប - ដីឥដ្ឋមានពណ៌ផ្សេងៗ លឿង ក្រហម ប្រផេះ)។ គេកិនកំទេចដីឥដ្ឋជាផង់បានដោយងាយ ។ កាលណាគេលាយទឹកនឹងដីឥដ្ឋ គេអាចច្របាច់ដីឥដ្ឋ ឲ្យជ្រាយស្មើសាច់ហើយសូន្យធ្វើជារបស់ផ្សេងៗឬជារូបភាពបានដោយងាយ ។

ដីឥដ្ឋជក់ទឹកកុំឲ្យជ្រាបបាន ហេតុនេះហើយបានជាស្រែណាដែលមានដីឥដ្ឋតែងមានទឹកដក់ ។

កាលណាគេយកដីឥដ្ឋមកដុតឲ្យឆ្អិន ដីនោះឡើងរឹងហើយប្រេះ ។

ដើម្បីកុំឲ្យប្រេះ គេត្រូវលាយខ្សាច់បន្តិចផង ។

គេយកដីឥដ្ឋពុំសុទ្ធធ្វើជាក្បឿង, ឥដ្ឋនិងកុម្ភការភណ្ឌ (Poterie) ។

គេប្រើដីឥដ្ឋសុទ្ធ (កៅឡាំង) ធ្វើជាគ្រឿងពរ្ស៊ីឡែន ។

## អាទិត្យទី ៣.– ដីខ្សាច់

មេរៀនសង្ខេប - ដីខ្សាច់មានគ្រាប់តូចៗពណ៌លឿងស្រួស ៗ គ្រាប់តូចៗនេះពុំជាប់ស្អិតជាមួយគ្នាដូចដីឥដ្ឋឡើយ គេអាចចាក់ដីខ្សាច់ឲ្យហូរបានដូចទឹក ។

ខ្យល់អាចបំបើងដីខ្សាច់ឲ្យហុយឡើងបាន ហេតុនេះបានជាគេឃើញពំនូកខ្សាច់នៅតាមឆ្នេរសមុទ្រ ៗ ដីខ្សាច់ពុំដក់ទឹកឡើយ ហើយពុំសូវមានជីជាតិផង ៗ គេប្រើដីខ្សាច់ក្នុងការធ្វើជំរងទឹក, ធ្វើបាយអ, ធ្វើកុម្ភការភណ្ឌ (Poterie) និងធ្វើកែវ ៗ

## អាទិត្យទី ៤– អំបិល

មេរៀនសង្ខេប – អំបិលមានជាតិប្រៃ ហើយរលាយឆាប់ណាស់ កាលណាគេដាក់នៅក្នុងទឹក បើគេយកទឹកនោះទៅដាក់ក្នុងចានហាល មិនយូរប៉ុន្មានគេនឹងឃើញទឹកហួតចេញអស់ នឹងមានគ្រាប់អំបិលក្ដាំងនៅបាតចាន ៗ

អំបិលមានពីរយ៉ាងគឺ អំបិលសមុទ្រនិងអំបិលកប់នៅក្នុងដី ៗ ដើម្បីនឹងធ្វើអំបិលសមុទ្រ គេបញ្ចូលទឹកសមុទ្រទៅក្នុងស្រែ ដែលគេហៅថាស្រែអំបិល ៗ គេទុកទឹកនោះឲ្យរីងខះនៅក្នុងស្រែនោះ ទើបគេកើបអំបិលមកប្រើការ ៗ

ឯអំបិលគប់នៅក្នុងដីជួនកាលនៅលើផ្ទៃផែនដី ។ អំបិលមានប្រយោជន៍យ៉ាងសំខាន់ក្នុងការចិញ្ចឹមជីវិតមនុស្សនិងសត្វ គេប្រើអំបិលក្នុងពេលធ្វើចំណីអាហារ ក្នុងការប្រឡាក់ទឹកក្នុងការឧស្សាហកម្ម ។

## វិធីបង្ការរោគ

### អាទិត្យទី ១— ជម្ងឺអុត

គោលសេចក្តី — ជាជម្ងឺធ្ងន់ហើយជារោគប្រចាំប្រទេសឥណ្ឌូចិន ច្រើនកើតនៅប្រទេសតុងកឹងនៅរដូវត្រជាក់ ។ ច្រើនកើតកូនក្មេងនិងមនុស្សធំ ។

១— លក្ខណៈ — ចាប់ឈឺក្បាល, ឈឺខ្លួន, ក្អួតហើយគ្រុនញាក់ ហើយក្តៅយ៉ាងខ្លាំង ។ រួចចេញកន្ទួលក្រហមពេញខ្លួននិងមុខ ។ មុខនិងត្របកភ្នែកឡើងហើម ។ បន្ទាប់មកកន្ទួលនោះមានខ្ទុះបែកហើយចេញខ្ទុកស្នាមអស់មួយជីវិត ។

២— ហេតុ — អតិសុខុមប្រាណនៅក្នុងខ្ទុះក្រម ឆ្លងដោយការប៉ះពាល់អ្នកជម្ងឺផង ដោយរុយ ។

៣– កិច្ចដែលត្រូវធ្វើក្នុងពេលកើតជំងឺ...

១– បញ្ជូនសិស្សឲ្យទៅពេទ្យកាលណាឃើញមានគន្ទួលលើខ្លួនវា

២ - ត្រូវបណ្ដុះអុតពល់លើកព្រោះកិច្ចនេះការពារពុំបានយូរទេ ។

៤– កិច្ចដែលត្រូវធ្វើចំពោះអ្នកជំងឺ...

១– ត្រូវដាក់មនុស្សជំងឺក្នុងកន្លែងមួយដោយឡែក ឲ្យមនុស្សដែលបានបណ្ដុះអុតហើយបំរើ – ដេញរុយកុំឲ្យចូលក្នុងបន្ទប់នោះ ។

៤– បង្ខាំងជំងឺក្នុងបន្ទប់ទាល់តែជ្រះស្រឡះ ។ ត្រូវដុតកន្ទេលខ្នើយហើយស្ងោរសំអានប្រដាប់ដែលអ្នកជំងឺបានប្រើ ។

## អាទិត្យទី ២ និងទី ៣ អន្តរាយបណ្ដាលពីសុរា ។

គោលសេចក្ដី –

សុរានាំឲ្យខូចសុខភាព – សុរាជាគ្រឿងពុលពុំមែនជាអាហារប្រសើរដូចអ្នកខ្លះស្មានឡើយ ។

សុរាបណ្ដាលឲ្យខូចក្រពះបាយមុនគេ ដោយបណ្ដាលឲ្យមានដំបៅដែលជាហេតុនាំឲ្យអាហារធាតុចេញពុំបានស្រួល (ការរំលាយអាហារធ្វើពុំបានស្រួលដូចធម្មតា – សុរាចូលទៅក្នុងឈាម – បេះដូងមានខ្លាញ់ដើរញាប់ពេកហើយពុំទៀងទាត់ផង ។ សរសៃឈាមឡើងរឹងពុំសូវយឺតនាំឲ្យឈាមរត់ពុំបានស្រួល ។

– ថ្លើមឡើងជាមានខ្លាញ់ពុកសួតរីង ។

– គ្រឿងប្រដាប់ខាងទឹកមូត្រក៏អន់ខ្សោយកំឡាំង ។

– សតិបញ្ញាក៏ទុនថយជួនទៅជាឆ្កួតក៏មាន ។

អ្នកសុរាសោណ្ឌ (អ្នកជាប់ស្រា) ពុំអាចទប់ទល់នឹងជម្ងឺបានឡើយ ។

ជម្ងឺរបេងបំផ្លាញអ្នកជាប់ស្រាច្រើនជាងជនដទៃ ។

អាទិត្យទី ៤.– រៀនសាដើម

---

អាគិកាដ្ឋាន

## វត្ថុស្វាធ្យាយន៍

អាទិត្យទី ១–. ស្ដាំ - ឆ្វេង

សុំមើលមេរៀនក្នុងសៀវភៅវត្ថុស្វាធ្យាយន៍ សំរាប់បរិវច្ឆណដ្ឋានទំព័រទី ១០៤,១០៥ នឹង ១០៦

អាទិត្យទី ២–. ប្រៃសនីយ៍, ទូរលេខ,

ទូរស័ព្ទមានខ្សែនឹងទូរស័ព្ទឥតខ្សែ

មេរៀនសង្ខេប គេផ្ញើដំណឹងកាន់គ្នាទៅវិញទៅមកដោយសំ-បុត្រឬដោយទូរលេខឬទូរសព្ទ ។

ដើម្បីនឹងផ្ញើសំបុត្រគេត្រូវបិទតែមតាមកំណត់ច្បាប់ហើយយកសំបុត្រនោះទៅដាក់ក្នុងប្រអប់សំរាប់ទទួលសំបុត្រនៅឯមន្ទីរប្រៃសនីយ៍ ។

នៅមន្ទីរនោះភ្នាក់ងារប្រៃសណីយ៍ចាត់ផ្ញើសំបុត្រនានា ទៅឲ្យអ្នកទទួលដល់ទីកន្លែងតាមអាស័យដ្ឋាន (ម.ថ-អាស័យ-យ៉ាត់-ដ្ឋានៈ (Adresse) ដោយរថយន្ត, រថភ្លើង, យន្តហោះឬដោយកប៉ាល់ ។

(សុំគ្រូយកស្រោមសំបុត្រមួយមកបង្ហាញសិស្សហើយបង្ហាញរបៀបការងារនិងរបៀបបិទតែម)

ទូរលេខជាគ្រឿងមួយបែបសំរាប់ផ្ញើដំណឹងបានយ៉ាងឆាប់ទាន់ចិត្ត ។ គ្រឿងនេះដើរដោយកម្លាំងអគ្គិសនីហើយភ្ជាប់ពីកន្លែងមួយទៅកន្លែងមួយដោយខ្សែលួសធ្វើពីលោហធាតុ ។ ជួនគេបង្កប់ខ្សែលួសនេះតាមបាតសមុទ្រឬទន្លេក៏មាន ។ ក្នុងការប្រើគ្រឿងនេះគេសន្មត់ប្រើគំនូសជំនួសព្យញ្ជនៈនានា ។

ឧទាហរណ៍. A=.—; B=.—.., C=.—.,

ទូរសព្ទមានខ្សែគឺគ្រឿងសំរាប់និយាយកាន់គ្នាដោយប្រើកម្លាំងអគ្គិស

នីដែរ ។ គេភ្ជាប់គ្រឿងនេះពីកន្លែងមួយទៅកន្លែងមួយដោយខ្សែលួស ធ្វើអំពីលោហធាតុដែរ ។

ឯទូរសព្ទឥតខ្សែគឺជាគ្រឿងសំរាប់ផ្ញើសព្ទឬសញ្ញាដែលគេសន្មតប្រើ តាមលំហអាកាសដោយឥតចាំបាច់ប្រើខ្សែឡើយ ។

## អាទិត្យទី ៣–. ម៉ាស៊ីនដើរដោយកម្លាំងចំហាយទឹក

ទឹកពុះក្នុងកំសៀវអាចធ្វើឲ្យគំរបកំសៀវរបើកបានមកពីកម្លាំងចំហាយទឹក ។ បើកាលណាគេយកបំពង់ដែកមួយមកដាក់ទឹកពាក់កណ្ដាល ហើយចុកឲ្យជិតរួចយកទៅកំដៅភ្លើង មិនយូរប៉ុន្មានទឹកនឹងពុះ បន្ទាប់មកគេនឹងឃើញឆ្នុកនោះខ្ទាតចេញជាពុំខានដោយសារចំហាយទឹកធាក់ ។

គឺកម្លាំងចំហាយនេះហើយដែលនាំឲ្យម៉ាស៊ីនកប៉ាល់, ម៉ាស៊ីនរថភ្លើង, ម៉ាស៊ីនកិនស្រូវ... បើកបរបាន ។ តែដើម្បីនឹងឲ្យទឹកពុះមានចំហាយគេត្រូវដុតធ្យូងឲ្យមានកំដៅខ្លាំង ។ ដូច្នេះសម្រេចទៅគឺភ្លើងធ្យូងទេ ដែលជាហេតុនាំឲ្យគ្រឿងម៉ាស៊ីនកប៉ាល់ឬរថភ្លើងដើរបាន ។

## អាទិត្យទី ៤ រថយន្តនឹងយន្តហោះ

ម៉ាស៊ីនបំពូកនេះមិនដើរដោយកម្លាំងចំហាយទឹកពុះឡើយ ។ គេដឹងថាគ្រោះថ្នាក់នឹងមានជាប្រាកដដល់ជនណាដែលកាន់ចង្កៀងឬចន្លុះ ដែលកំពុងឆេះមានអណ្ដាតចូលទៅក្នុងកន្លែងណាមួយ ដែលមានចំហាយ

ប្រេងសាំងព្រោះចំហាយប្រេងសាំងនឹងខ្យល់លាយគ្នាតែកាលណាមកប៉ះអណ្ដាតភ្លើងនឹងឆេះហើយផ្ទុះផង ។

អ្នកប្រើចង្កៀងដុតស្រាចាស់ពេកឬខូចក៏មានគ្រោះថ្នាក់ដែរពីព្រោះចំហាយស្រាដុតលាយនឹងខ្យល់តែប៉ះនឹងអណ្ដាតភ្លើងក៏ឆេះហើយផ្ទុះដែរ ។ គឺកម្លាំងដែលប្រេងសាំង ។

គឺកម្លាំងដែលប្រេងសាំងនឹងខ្យល់ឆេះផ្ទុះនេះហើយដែលជាហេតុនាំឲ្យម៉ាស៊ីនរថយន្តនឹងម៉ាស៊ីនយន្តហោះដើរបាន ។

## វិធីបង្ការរោគ

### អាទិត្យទី ១.-- ដង្កូវនៅក្នុងពោះវៀន = ព្រូន

គោលសេចក្ដី ១ លក្ខណៈព្រូនធម្មតា - គឺជាដង្កូវខ្លួនវែងសណ្ឋានជន្លេនតែស្រួចចុងដើមមានប្រវែងដល់ ៣០ ស.ម. ក៏មាន ។

២-- ដំណើរកំណើតព្រូន - ពងវាចូលទៅក្នុងខ្លួនមនុស្សតាមបន្លែស្រស់ឬតាមទឹកឆៅ - ពងនោះញាស់ជាកូននៅក្នុងពោះវៀន ។ លុះកូនធំឡើងវាពងបន្តជាប់ពងនោះធ្លាក់មកក្រៅតាមលាមក - បើពងនេះទៅប៉ះ

របស់អ្វីដែលមនុស្សបរិភោគ ពងនោះនឹងញាស់ក្នុងពោះមនុស្សនោះបន្ត មកទៀត ។

៣– ហេតុនាំឲ្យដឹងមានព្រូនក្នុងខ្លួន – ជួនកាលមានព្រូនចេញតាមបាតឬតាមមាត់ - កាលណាព្រូនមានច្រើនក្នុងពោះ វាបណ្ដាលឲ្យចុកពោះឲ្យចុះរាគឲ្យក្អួតឬឲ្យគ្រុន ។ បើកូនក្មេងវាបណ្ដាលឲ្យដេកបេះតែភ្ញាក់កន្ត្រាកដៃជើងជួនឲ្យប្រកាច់ ជាស្កន់ជាន់ក៏មាន ។

៤– កិច្ចការពារ

ក) អាស្រ័យតែទឹកដាំ, តែបន្លែឆ្អិន ឬស្រុសទឹកក្ដៅឲ្យស្អាត ។

ខ) កប់លាមកអ្នកជម្ងឺឆ្ងាយពីបឹងបួ ឬពីផ្លូវទឹក ។

គ) លាងដៃក្រោយពេលដែលបានប៉ះពាល់ប្រដាប់មនុស្សជម្ងឺប្រើ ។

## អាទិត្យទី ២ ដង្កូវនៅក្នុងពោះវៀន (ត) ព្រូនវែង

**គោលសេចក្ដី ·– ក) លក្ខណៈ** ដង្កូវរាងសំប៉ែតរស់នៅក្នុងពោះវៀនមនុស្សមានប្រវែងជួនដល់ ១០ ឬ ២០ ម. ខ្លួនវាមានថ្នាំងៗ ថ្នាំងធំៗ នៅខាងកន្ទុយ - ក្បាលតូចមានទំពក់សំរាប់តោងយ៉ាងស្អិត - វាច្រើនឆ្លងមកមនុស្សតាមសាច់ជ្រូក ។

**១) ដំណើរកំណើតព្រូន–** ថ្នាំងធំៗដែលពេញដោយពងដាច់ចេញមួយម្ដងៗហើយចេញមកក្រៅតាមលាមក ។ ពងនេះចំរើនអាយុ

បានលុះណាតែបានចូលទៅក្នុងខ្លួនជ្រូកឬគោដែលវាទៅនៅតោងជាប់នឹងសាច់សត្វនោះ ។ កាលណាយើងស៊ីដោយសាច់សត្វនេះមិនឆ្អិនល្អព្រូននេះនឹងកើតក្នុងខ្លួនយើង ។

### គ) ហេតុដែលនាំឲ្យដឹងជាមានព្រូននេះនៅក្នុងខ្លួន

អ្នកមានព្រូនក្នុងខ្លួនបរិភោគច្រើនតែចេះតែស្គមជាលំដាប់ ។ គេឃើញមានចំណែកខ្លួនព្រូនជាថ្នាំងៗនៅក្នុងលាមក ។

ឃ) កិច្ចការពារ– មានតែកិច្ចមួយយ៉ាងសំខាន់គឺត្រូវបរិភោគតែសាច់ជ្រូក ឬគោដែលគេបានចំអិនយ៉ាងឆ្អិនបំផុត ។

## អាទិត្យទី ៣ ការអន្តរាយបណ្ដាលពីបារីនិងអាភៀន

គោលសេចក្ដី ថ្នាំមានជ័រដែលជាគ្រឿងពុល ។ ជ័រនេះបណ្ដាលឲ្យខូចធ្មេញឲ្យឈាមរត់ពុំស្រួលនឹងនាំឲ្យការដកដង្ហើមព្រមទាំងការរំលាយអាហារដើរពុំបានស្រួលផង ។ ការជក់បារីច្រើនហួសបណ្ដាលឲ្យខូចសុខភាព ។

ឯចំណែកអាភៀនមានជ័រខ្លាំងជាងថ្នាំទៅទៀត ។ ក្រៅពីអន្តរាយធ្ងន់ដែលអាភៀនបណ្ដាលខាងផ្លូវចិត្ត អាភៀននាំឲ្យខូចគ្រឿងប្រដាប់ក្នុងខ្លួនមនុស្សជាច្រើន ។ អ្នកជក់អាភៀនជាប់បរិភោគអ្វីក៏ពុំបាន ឡើងស្គាំងស្លេកហើយចេះតែស្គមទៅៗព្រោះជ័រអាភៀនបំពុលឈាម ។

គោងយើងបំបាត់ជំនឿមួយដែលថាអាភៀនជាឱសថសំរាប់កែរោគសួតបានយ៉ាងចំណាន អាភៀនគ្រាន់តែឲ្យស្រាកជម្ងឺតែមួយភ្លែតប៉ុណ្ណោះ បន្ទាប់មកជម្ងឺនឹងរឹតតែខ្លាំងឡើងទៀត ។

អាទិត្យទី ៤.– អន្តរាយបណ្ដាលពីសុរា ។ នឹងរៀនសាដើម ។

ចំពោះអន្តរាយបណ្ដាលពីសុរា ។ សុំគ្រូមើលស្រង់សេចក្ដីពីមេរៀនក្នុងទស្សនាវដ្ដីនេះត្រង់ទំព័រសំរាប់មធ្យមដ្ឋានទី១ –

---

កុមារដ្ឋាន

## វិត្តស្វាធ្យាយន៍

### អាទិត្យទី ១.– អំពីផែនដី

មនុស្សយើងនឹងសត្វ ដើមឈើរស់នៅលើដី ផ្ទៃដីស្មើរហូតឬមួយយ៉ាងណា? មានកន្លែងខ្លះខ្ពស់កន្លែងខ្លះទាប នៅកន្លែងណាដែលផ្ទៃដីខ្ពស់? នៅកន្លែងភ្នំ ។ នៅកន្លែងណាដីទាប? នៅមាត់ទន្លេមាត់សមុទ្រ ។

គេច្រើនដាំដំណាំនៅទីដីខ្ពស់ឬមួយនៅវាលទំនាប ៗ ពេលណាភ្លៀងរួច ឯងសង្កេតឃើញអ្វីនៅកន្លែងទួល? អ្វីនៅកន្លែងទំនាប? ទឹកភ្លៀងច្រោះដីទួលនាំយកអ្វីមកដាក់ទីទំនាប ?

អាទិត្យទី ២.– អំពីមេឃ

អាទិត្យទី ៣ – អំពីផ្កាយ

អាទិត្យទី ៤.– អំពីព្រះអាទិត្យ

សូមគ្រូមើលក្នុងសៀវភៅវិជ្ជាខេមរភាសាសម្រាប់ថ្នាក់បរិច្ឆណដ្ឋាន ៗ

## វិធីបង្ការរោគ

សាបស្រៀនពីដើមឡើងវិញ

---

បរិច្ឆណដ្ឋាន

## វិត្តស្វាធ្យាយន៍

អាទិត្យទី ១ អំពីអាកាស

សុំឲ្យគ្រូរកផ្តិតមួយ ទឹកមួយបានក្តាំ កែវទឹកមួយឬកូនដបមកបញ្ចាក់បញ្ជ្រៀន ឲ្យសិស្សយកសៀវភៅ ឬផ្តិតបក់មុខវាមានអ្វីមកប៉ះមុខឯង? កាលណាឯងរត់លេងហេតុដូចម្តេចបានជាអាវឯងប៉ោងធំឡើង? ឲ្យយកកែវទឹកទទេ ផ្កាប់ហើយជ្រមុជទៅក្នុងទឹកបាន ទឹកចូលពេញកែវឬទេ? ហេតុអ្វី? ផ្អៀងកែវបន្តិច ឃើញហេតុយ៉ាងណា? មានពពុះផុសចេញពីកែវ ហើយឡើងមកបែកលើទឹក ពពុះនោះគឺអ្វី? បើដូច្នេះអា-កាសមាននៅឯណាខ្លះ? គ្រប់កន្លែងសូម្បីតែប្រហោងតូចក៏មានអាកាសដែរ កាលណាយើងដកដង្ហើម យើងសំគាល់ក្លិនអាកាសដែលចេញចូលបានឬទេ? យើងមើលឃើញអាកាសគ្មានពណ៌ គ្មានក្លិន ។ -

ប្រយោជន៍នៃអាកាស មនុស្សដែលលង់ទឹកដែលចងក ហេតុអ្វីបានជាស្លាប់? បើយកចាបមួយទៅគ្របឲ្យជិតកុំឲ្យអាកាសចូលបានបក្សីមុខជានឹងស្លាប់ បើដូច្នេះមនុស្សសត្វនឹងរុក្ខជាតិត្រូវការនឹងអាកាស អុជទៀនមួយឲ្យឆេះហើយយកចំពង់មួយគ្របឲ្យជិត ឯងឃើញហេតុយ៉ាងណា? ទៀនរលត់ពីព្រោះអ្វី? គ្មានអាកាសនឹងឲ្យឆេះ ដូច្នេះតែគ្មានអាកាស វត្ថុផ្សេង ៗ មិនអាចនឹងឆេះបានឡើយ ។

មេរៀនសង្ខេប.— អាកាសមាននៅគ្រប់តម្បន់ អាកាសគ្មានពណ៌ គ្មានក្លិន ។ អាកាសនឹងជួយទ្រទ្រង់ជាតុមនុស្សសត្វនឹងរុក្ខជាតិផងទាំងឡាយ ។ តែគ្មានអាកាស ភ្លើងពុំអាចនឹងឆេះបានឡើយ ។

## មេរៀនទី ២.– អំពីទឹកនិងភ្លៀង

## អាទិត្យទី ២.– អំពីពពក

សុំគ្រូរកឆ្នាំងតូចមួយ កូនជើងក្រានមួយនិងចានទាបមួយមកធ្វើឲ្យសិស្សពិនិត្យហើយនិងរកឲ្យឃើញហេតុ ។

ការធ្វើឲ្យមើល ។

ដាក់ទឹកទៅក្នុងឆ្នាំងហើយដាំឲ្យពុះ លុះទឹកពុះបើកគ្របឡើង ។ អ្វីដែលហុយពីឆ្នាំងឡើង ។ ចំហាយទឹកហុយឡើង ។ ចំនួនទឹកក្នុងឆ្នាំងក៏ថយ ។ យកចានទាបដាក់លើមាត់ឆ្នាំង ចំហាយទឹកហុយទៅប៉ះហើយកកទៅជាដំណក់ទឹក ។ វេលាដែលក្ដៅ ទឹកទន្លេ-បឹង-សមុទ្រហួតឬទេ? ចំហាយទឹកដែលហួតបង្កជាអ្វី? ហេតុដូចម្ដេចបានជាពពកអណ្ដែត? ហេតុដូចម្ដេចបានជាទៅជាភ្លៀងបាន ។ កាលណាពពកអណ្ដែតទៅប៉ះនឹងអាកាសត្រជាក់ ចំហាយទឹកនៅក្នុងពពកក៏កកទៅជាគ្រាប់ភ្លៀងធ្លាក់មកលើដី ។ ដល់ភ្លៀងរួច ទឹកភ្លៀងនោះហូរជ្រាបទៅក្នុងដីមួយបែបទៀត ហូរដាក់ទៅក្នុងទន្លេធ្លាក់ទៅក្នុងសមុទ្រវិញដដែល ។

ពពកខ្លះស ខ្លះជាផ្ទុំងខ្មៅ ជួនកាលមានរូបពងប្លែក ហើយមានពណ៌ផ្សេង ៗ តាមព្រះអាទិត្យ ពពកដែលបង្កើតជាភ្លៀងធ្លាក់មកនោះ គឺពពកខ្មៅទាបនឹងដី ។

មេរៀនសង្ខេប–. ដោយចំហាយព្រះអាទិត្យទឹកក៏ហួតហើយកើតទៅជាចំហាយទឹក អណ្តែតផ្តុំគ្នាបានជាពពករសាត់តាមខ្យល់ ពពកមានប្លែកៗពីគ្នាតាមកំពស់តាមពេលវេលា កាលណាអណ្តែតទៅប៉ះលើអាកាសត្រជាក់ ពពកក៏កកទៅភ្លៀងធ្លាក់ចុះមក ។

## អាទិត្យទី ៣.– របៀបចែកពេលវេលាតាមបារាំងសែស

សុំគ្រូរកប្រក្រតីទិនបារាំងខ្មែរមកឲ្យសិស្សមើលថ្ងៃខែផង ។

របៀបបង្ហាញ កំណត់ពេលវេលាក្នុងមួយថ្ងៃ ពីអធ្រាត្រទៅទល់នឹងថ្ងៃត្រង់ហៅថាព្រឹក ពីថ្ងៃត្រង់ទៅទល់នឹងអធ្រាត្រហៅថាល្ងាច ។ ពេលនីមួយៗមាន ១២ ម៉ោង មួយម៉ោងមាន ៦០ មីនុត មួយមីនុតមាន ៦០ សឹកុង ។

ក្នុងមួយឆ្នាំមាន ១២ ខែ ឲ្យរាប់នៅលើប្រក្រតីទិន ខែនីមួយៗមាន ៣០ ឬ ៣១ ថ្ងៃ លើកតែខែហ្វេវ្រីយេដែលមានតែ ២៨ ឬ ២៩ ថ្ងៃ ក្នុងមួយឆ្នាំមាន ៣៦៥ ថ្ងៃឬ ៣៦៦ ថ្ងៃ ។

## អាទិត្យទី ៤.– គិតពេលវេលាតាមរបៀបខ្មែរ

ឲ្យរកមហាសង្ក្រាន្តខ្មែរមកបង្ហាញឲ្យបេះមើលថ្ងៃខែខ្មែរផង ។

របៀបខ្មែរ ចែកថ្ងៃនិងខែ មួយថ្ងៃមាន ២៤ ម៉ោង គឺព្រឹក ១២ ម៉ោង

ល្ងាច ១២ ម៉ោង ខែខែកជាពីរចំណែកគឺខ្នើត ១៥ ថ្ងៃ រនោចមាន ១៤ ឬ ១៥ ថ្ងៃ ថ្ងៃ ១៥ កើតគេហៅថាថ្ងៃពេញបូណ៌មី ពីព្រោះយប់ថ្ងៃនោះ ព្រះច័ន្ទភ្លឺពេញវង់ ថ្ងៃ ១៤ ឬ ១៥ រោចគឺខែដាច់ ដូច្នេះក្នុងមួយខែខ្មែរ មាន ២៩ ឬ ៣០ ថ្ងៃជាកំណត់ដរាប ។

ក្នុងមួយឆ្នាំមាន ១២ ខែឲ្យមើលលើមហាសង្ក្រាន្តខ្មែរ គឺខែមិគសិរ បុស្ស-មាឃ-ផល្គុណ ចេត្រ ពិសាខ ជេស្ឋ អាសាឍ ស្រាពណ៍ ភទ្របទ អស្សុជ នឹងកត្តិក ឲ្យរៀនសំគាល់លេខខែផង ជាការមាន ប្រយោជន៍ ក្នុងសំបុត្រស្នាមដូចគេសរសេរថា ថ្ងៃ ២ ៣ ១ គឺជាថ្ងៃច័ន្ទ ៣ រោចខែមិគសិរ ។

---

បរិច្ចណាដ្ឋាន

## វិធីបង្ការរោគ

អាទិត្យទី ១.– អំពីមូស

មើលក្នុងសៀវភៅវិធីបង្ការរោគ ទំព័រលេខ ៤១ - ៤២ - ៤៣ - ៤៤

អាទិត្យទី ២–. អំពីគ្រុនចាញ់

គ្រុនចាញ់ច្រើនមាននៅស្រុកណាដែលមានថ្លុកត្រពាំងបឹងបួរតំបន់ព្រៃ តំបន់ភ្នំនៅស្រុកក្ដៅ ជម្ងឺនេះមានលក្ខណៈគ្រុនលោះឈឺក្បាល ពោយដៃជើង វាបណ្ដាលឲ្យស្លាប់ផង ជម្ងឺគ្រុនចាញ់បណ្ដាលអំពីមេរោគមួយយ៉ាងល្អិត ដែលមូសវានាំពីមនុស្សគ្រុន បម្លងមកដល់មនុស្សជា ។

ដើម្បីនឹងជៀសវាងកុំឲ្យមូសខាំបាន ត្រូវដាក់មុង ហើយបំផ្លាញជន្លូវទឹកដោយប្រេងកាតឬលែងត្រីឲ្យស៊ីឬដាំស្រូវ ។

បើឈឺគ្រុនចាញ់ត្រូវលេបឬចាក់គីនីនទើបបានជា ។

## អាទិត្យទី ៣ អំពីជម្ងឺពិស

សូមមើលសៀវភៅវិធីបង្ការរោគទំព័រលេខ ៤៥ ។

---

លោកនីតិ

## សម្រាប់ឧត្ដមដ្ឋន

របៀបចាត់ចែងខាងហិរញ្ញវត្ថុក្នុងព្រះរាជអាណាចក្រកម្ពុជា ។

## មេរៀនទី ១.– ថវិកាគាគា

ដែលហៅថាថវិកា គឺប្រាក់ចំណូលនឹងចំណាយនៃរដ្ឋ,ក្រុង-ខេត្ត ឃុំឬរបស់ឯកជនណាមួយ ។

នៅក្នុងវង្សត្រកូលនិមួយ ៗ ស្ត្រីមេផ្ទះ គត់មត់ល្អ ត្រូវដឹងធនធានដែលខ្លួនមាន ៗ គេប្រុងប្រយ័ត្នក្នុងការចាយវាយដោយលែលកមិនឲ្យចំណាយលើសលុបលើធនធានខ្លួនឡើយ ប្រព្រឹត្តបែបនេះហៅថារៀបចំថវិកាខ្លួន ៗ ឯរដ្ឋ ក្រុង ខេត្ត ឃុំក៏ធ្វើដូចស្ត្រីមេផ្ទះនេះដែររាល់ឆ្នាំគឺរៀបចំថវិកាដែលបែកជាពីផ្នែកៈ ចំណូលនឹងចំណាយ ៗ

នៅប្រទេសកម្ពុជាមានថវិកាឃុំ ថវិកាខេត្ត ថវិកាក្រុងនឹងថវិកាជាតិសំរាប់ប្រទេសទាំងមូល ៗ

ចំណូល— ប្រាក់ចំណូលនៃថវិកាទាំងនេះកើតឡើងពីផ្នែកច្រើន ៗ ផ្នែកចំណូលធំជាងគេ គឺផ្នែកខាងពន្ធនឹងអាករ ៗ

ផ្នែកចំណូលដ៏សំខាន់កើតមកពីៈ

ក) ផលនៃប្រាក់បន្ថែមភាគរយ (ប្រាក់បន្ថែមភាគរយគឺចំនួនប្រាក់ដែលរាជការឲ្យហូតយកជាចំណូល នៃថវិកាឃុំ ខេត្តឬថវិកាក្រុង)

ខ) ផលនៃផែនរាជការ ( ផាសុីផ្សារ ឈ្នួលដី ។ល។

គ) ផលនៃអាករឃុំឬអាករខេត្ត;

ឃ) ផលនៃការលក់ពិន័យផ្សេង ៗ

ង) ផលនៃការលក់ទ្រព្យសម្បត្តិរាជការ;

ច) ផលកើតអំពីទានឬអច្ច័យទានទាំងឡាយ ;

ង) ជូនកាលថវិកាខេត្តបានប្រាក់ជំនួយមកពីថវិកាជាតិ ហើយថវិកាឃុំ បានប្រាក់ជំនួយមកពីថវិកាខេត្តដូច្នេះក៏មាន ៗ

ចំណាយ.– ចំណូលទាំងឡាយនៃថវិកាផ្សេង ៗ នេះសំរាប់ចាយវាយសឹងមានមុខដូចរាយតទៅ ៖

ក) ចំណាយសំរាប់ការប្រព្រឹត្តទៅនៃក្រសួងសាធារណៈផ្សេង ៗ ហើយនិងចំណាយជាប្រយោជន៍ចំពោះប្រទេស (ក្រុមរាជការប៉ូលិស គ្រឹស្ថានសិក្សា ការថែទាំថ្នល់គ្រឹស្ថានរាជការ ក្រុមវិថីបាល )

ខ) ចំណាយសំរាប់សង្គមកិច្ច (ជំនួយដល់ពលរដ្ឋមានអាសន្នអត់បាយ ទឹកលិចឬភ្លើងឆេះផ្ទះ ៗ ល ៗ

មេរៀនទី ២.– ថវិកាជាតិ-ប្រាក់ចំណូលខាងថវិកាជាតិបានមកអំពី ៖

ក) ពន្ធចំពោះដូចជាពន្ធជួយជាតិ ដែលរាជការបំបាត់ចោលកាលពីឆ្នាំ ១៩៤៩, ពន្ធដី, ប៉ាតង់, ពន្ធលើនេសាទុបករណ៍ ៗល ៗ

ខ) ពន្ធមិនចំពោះដូចជាពន្ធហួតលើការលក់ទំនិញដែលរាជការកាន់ការផ្តាច់មុខ (អំបិល, អាភៀន) ពន្ធឧបភោគបរិភោគអាករលើផលរបរ ៗ ល ៗ

គ) ពន្ធកន្លែងចាប់ត្រី អាករលើផលក្នុងប្រទេសដែលត្រូវដឹកនាំទៅប្រទេសក្រៅ ពន្ធក្នុងព្រៃ ។ល។

ឃ) ចំនួនប្រាក់ខ្លះដែលថវិកាសហរដ្ឋបង្វិលជាជំនួយមកឲ្យ (Ristournes) ប្រាក់ចំណូលទាំងនេះសំរាប់ចាយវាយសំខាន់មានមុខដូចកយតទៅ ៖

ក) ចំណាយសំរាប់ការប្រព្រឹត្តទៅនៃក្រសួងសាធារណៈផ្សេងៗ តុលាការ រដ្ឋសភាមន្ទីរស្តីការរដ្ឋមន្ត្រីក្រសួងជាតិផ្សេងៗ

ខ) ជំនួយប្រាក់ចំពោះថវិកាក្រុងហើយនិងថវិកាខេត្ត ។

គ) ចំណាយសំរាប់ធ្វើឲ្យប្រទេសបានចំរើនខាងសេដ្ឋកិច្ច (ការស្ថាបនាថ្នល់ទំនប់មជ្ឈមណ្ឌលនៃការស្វែងរកខាងសេដ្ឋកិច្ច ការជីកព្រែក ការបណ្ដុតពោងតាមផលមគ្គ ។ល ។

ឃ) ចំណាយសំរាប់កងទ័ព–

ង) ចំណាយសំរាប់សង្គមកិច្ចផ្សេងៗ ការសិក្សានិងអប់រំប្រជាជន, ការរំងាប់ជម្ងឺទាំងពួង ។ល។

អាករគយអាករប្រៃសណីយ៍ទូរលេខ ទូរស័ព្ទ តម្លៃតែមនិងចុះបញ្ជីការព្រមទាំងផលឬអាករអ្វីផ្សេងទៀតមិនបានជាចំណូលមកក្នុងថវិកាជាតិ

អាករទាំងអំបាលនេះចូលទៅខាងថវិកាសហារជ្ឈ ។ លុះនៅពេលដាច់ឆ្នាំ
ម្ដងៗទើបប្រទេសខ្មែរទទួលពីថវិកាសហារជ្ឈនេះនូវចំនួនប្រាក់មួយផ្នែកជា
ប្រាក់បង្វិលមក (Ristournes)

## មេរៀនទី ៣.- ពន្ធបំពោះនិងពន្ធមិនបំពោះ

ពន្ធជាចំនួនប្រាក់មួយដែលមនុស្សដំពូកខ្លះបង់ជូនរាជការ ដើម្បីជា
ប្រាក់សំរាប់ចាយក្នុងការសាធារណៈ ។

ពន្ធមានពីរយ៉ាង៖ ពន្ធបំពោះ និងពន្ធមិនបំពោះ

ពន្ធបំពោះគឺពន្ធបំពោះ ឈ្មោះមនុស្ស ។ រាជការរាយឈ្មោះមនុស្ស
ជាប់ពន្ធទាំងនោះក្នុងបញ្ជីមួយដែលភ្នាក់ងាររាជការធ្វើទុកជាមុន ។

១– មនុស្សបង់ពន្ធដើម្បីនឹងធ្វើដំនួញឬដើម្បីនឹងប្រព្រឹត្តទៅនូវការ-
ចិញ្ចឹមជីវិតផ្សេងៗ, ពន្ធដែលមនុស្សនោះបង់ហៅថាពន្ធបំពោះ ។

ពន្ធមិនបំពោះ គឺពន្ធដែលរាជការហូតយកមិនបំពោះពីឈ្មោះ
មនុស្សណាឡើយ ។

២– កាលណាអ្នកទិញបារីមួយកញ្ចប់អ្នកចេញប្រាក់សំរាប់ថ្លៃបារី-
ផង សំរាប់អាករពិសេសមួយយ៉ាងផង ។

អ្នកជៀសវាងមិនបង់អាករនេះបាន កាលណាអ្នកមិនបេះជក់បារី ។
បើកាលណាអ្នកត្រូវការបារីអ្នកត្រូវតែបង់ ។

រាជការហូតពន្ធនេះមិនចំពោះពីឈ្មោះមនុស្សណាឡើយ គឺហូតយកចំពោះតែអំពើនៃមនុស្សទូទៅ ៗ

ពន្ធចំពោះសំខាន់ ៗ គឺ៖ ពន្ធដី - អាករលើផលរបរ ដម្លៃប៉ាតង់ត៍ ពន្ធរទេះពន្ធសត្វ ៗ ល ៗ

ពន្ធមិនចំពោះសំខាន់ៗ គឺ៖ ពន្ធទំនិញដែលដឹកចេញឬនាំចូល-អាករប្រៃសណីយ៍ទូរលេខ ទូរស័ព្ទ ដម្លៃតែមនិងចុះបញ្ជីការ អាករលើឧបភោគបរិភោគ (ពន្ធឆ្នាំស្រា ឈើគូស ៗ ល ៗ អាករលើផលរបរ ៗលៗ

## មេរៀនទី ៤.— ការផ្តាច់មុខនិងការរត់គយ

ការផ្តាច់មុខគឺជាសិទ្ធិបើកឲ្យដល់ឯកជនទិញ ជួញឬលក់ទំនិញអ្វីមួយផ្តាច់មុខតែម្នាក់ឯង ៗ ដូចជាជនឯទៀតដែរ រាជការទិញទំនិញទាំងពីរមុខនេះនៅក្នុងប្រទេសយើងឬពីប្រទេសក្រៅហើយ យកមកលក់ឲ្យជនអ្នកត្រូវការតាមដម្លៃដែលរាជការតម្រូវ ៗ រាជការអាចអនុញ្ញាតឲ្យមនុស្សខ្លះលក់ទំនិញបំពូកនេះ ជំនួសរាជការក៏បាន ៗ

ចំណែកខាងអំបិល រាជការបើកអំណាចឲ្យមនុស្សខ្លះធ្វើក្នុងស្រែអំបិលជាច្រើនតែអំបិលដែលធ្វើកើតឡើងទាំងអំបាលម៉ានម្ចាស់ស្រែអំបិលទាំងអស់ត្រូវលក់ឲ្យតែរាជការ រួចទើបរាជការយកមកលក់ឲ្យអ្នកត្រូវការ

គេទៅទៀត ។ ការរត់គយ គឺការនាំចូលឬលក់លួចលាក់ទំនិញទាំងឡាយដែលរាជការកាន់ការផ្តាច់មុខ ។

គេទុកការនេះជាការរត់គយដែរ ជនណានាំចូលឬលក់ទំនិញអ្វីដែលរាជការហាម ( ដូចជាកាំភ្លើង, គ្រាប់រំសេវជាដើម ) ឬទំនិញណាដែលជាប់ពន្ធគយ ។

ការនាំទំនិញខ្លះចេញទៅប្រទេសដទៃដោយលួចលាក់ជាការរត់គយដែរ ។

អំពើអ្នករត់គយដែលប្រាថ្នាបង់ ឲ្យទំនិញខ្លួនផុតពីពន្ធគយគឺជាអំពើទុច្ចរិតមួយ ។

តុលាការ ធ្វើទោសជាទម្ងន់ដល់មនុស្ស រត់គយទាំងឡាយ ។

## មេសូត្រត្រូវមាត់

(សំរាប់គ្រប់ថ្នាក់)

### ១- អំពីពេលវេលា

ព្រះធរណី ឬក៏ប្រឹថពី វិលជុំខ្លួនឯង
ឬវិលជុំវិញ អាទិត្យសូរ្យសែន ទាំងពីរនេះឯង

ហៅពេលវេលា ៗ វិលបានមួយជុំ រួបរួមបូកផ្តុំ
សម្រេចត្រូវជា មួយថ្ងៃមួយយប់ បើរាប់នាឡិកា
ពិតទៅត្រូវជា ម្ភៃបួនម៉ោងចាំ ៗ វិលគ្រប់ឡើងពិត
ជុំព្រះអាទិត្យ ហៅថា ១ ឆ្នាំ បើគិតជាថ្ងៃ
បីរយហុកប្រាំ ឬក៏ចំណាំ ហាពីរអាទិត្យ ៗ
គ្រប់ឆ្នាំតែងផ្លាស់ ប្តូរខ្យល់អាកាស តាមបានពិនិត្យ
ដែលគេហៅថា រដូវបីពិត តុំទឹងថេរបិត
ផ្លាស់ពិតប្តូរគ្នា - ៗ

ពាក្យពន្យល់.—

ធរណី=(ម.ថ ធរៈនី) ផែនដី ៗ

ប្រឹថពី=(ម.ថ ប្រឹថៈ-ពី) ផែនដី ៗ

សូរ្យសែន=(ម. សូ.សែន) ពន្លឺព្រះអាទិត្យ ៗ

## អំពីការជាងស្មិត

លោហធាតុជាងដុត លោយសុសសុទ្ធ ចាក់ក្នុងពុម្ពមួយ
ក្លាយជាសណ្ឋាន មូលវែងជ្រុងជ្រោយ ទទឹងបណ្តោយ
ឲ្យដូចជាពុម្ព ៗ ត្រជាក់កាលណា ដែកស្មិតលាយគ្នា

គេដាក់មួយដុំ　គឺលាយច្បូង, ស្ពាន់　សំណផ្គួបផ្គុំ
សង្កសីបំរុង　ប្រើការច្រើនយ៉ាង ៗ　អ្នកស្រុកអាយគេ
ពុំសូវធ្វើទេ　ចំណែកប៉ែកខាង　នៅឥណ្ឌូចិន
គ្រឿងស្ពិតបាំង　បំរុងធ្វើខ្នាំង　ខ្ទះបាយជាអាទិ៍ ៗ

## ពាក្យពន្យល់.–

សណ្ឋាន= (ម.ថ សន់-ឋាន) ករ៍រៅ ៗ

លោហធាតុ= ធាតុដែក - ស្ពាន់, សំណ ៗល ៗ

ជាអាទិ៍ = ជាដើម ៗ

## ៣– អំពីត្បូតត្រី

នៅក្នុងសកលលោក　មានគេគោគត្បូតត្រី –
ថែបចាស់ថែបសម័យ　សុវិល័យនៃខេមរៈ ៗ
គ្រឿងក្លែងគឺអ្នកប្រាជ្ញ　ដែលអង់អាចឈ្លាសតិទ័គ្ន
បារ៉ែយ៉ាងឯកអគ្គ　បង្កើតឆ្លាក់តាមពិចារណ៍ ៗ
គង់ស្គរទ្រសម្ភោរ　រនាតកេទសូរសព្ទ
ពីពេះអស់សោតា　ខ្ញុំយើមជាក្រែងតាំងអស់ ៗ
សាយជៀវនឹងចាប៉ី　ទ្រខ្សែបីក្រពីពេះ
ថែបមកកំណត់ឈ្មោះ　នគររាជប្តាស្តេចផ្គុំ ៗ

ពាក្យពន្យល់._

តូរ្យតន្ត្រី = (ម-ថ ដូ-ដន់-ត្រី) គ្រឿងភ្លេងដេញដំ ផ្លុំកូត ។ បវរ = (ម-ថ ប-វ៉ៈ) ប្រសើរ ។ ឯកអគ្គ = (ម-ថ អ័ក) ប្រសើរយ៉ាងឯក ។ ពិចារណ៍ = (ម.ថ.ចា) ពិនិត្យ ។ សត្តា = (ម.ថ ស័ត-តា) សំឡេង ។ សោតា = ត្រចៀក ។

## ៤_ អំពីរបាំ

របាំពិចាក់ក្បាច់ កាយក្រមាប់ធ្មៀងនេត្រា
ដើងឈានរាំសហគ្នា បោកកេសាញាក់ស្មាធង ។
ច្រៀងកំតាមសទ្ទជាតិ ស្នូរពិណពាទ្យនោតគង
ប្តៃលតាមទំនង ពោលចាចង់ប្រសង្គា ។
កើតទុក្ខសុកស្មាញចិត្ត យន់គំនិតក្តងអាត្មា
របាំកិច្ចរចនា អាចការពារឲ្យក្លាហាន ។
បុត្របុរសតែង ពោលចាចែងបង្កើតមាន
កើតសត្រូវគ្រប់ទីឋាន គេរាប់អានថ្កើងថ្កានអីយ ។

ពាក្យពន្យល់.-

នេត្រា = ភ្នែក ។ ហត្ថា = ដៃ ។

កេសា = សក់ ។ សត្វជាតិ = (អ.ថ

ស័ត-ទ:-ជាតិ) សំឡេង ។

បុព្វបុរស = បុរសជាន់ដើម ។

ចាចៃន៍ = ថ្វាថ្វៃន៍ ។

## ៥- កំណាព្យ

បណ្ឌិតកវីថ្លាស    ប្រសប់ណាស់ពាក្យកាព្យឃ្លោង

មានវគ្គថ្នាក់ឃ្លាគ្រោង    សមប្រគោងទាញហេតុផល ។

ចុងចួនជាប់សម្ពស្ស    សេចក្តីស្រស់ឧបាយកល

ឥតមានលាយប្របល់    ដែលអំពល់ស្តាប់មិនបាន ។

ខ្វះបែបសន្ធើបខ្វី    ពិស្តារក្តីសឹងដំមាន

ពាក្យចាស់ពីបូរាណ    ដូចដែលមានក្នុងសាស្ត្រា ។

កើរកាលប្តូរច្បាប់ក្រម    ប្តូរធម្មក្រិត្យា

ឬមានក្នុងសាស្ត្រា    ល្បែងនានាពាក្យកាព្យឃ្លោង ។

រោងពុម្ពខ្មែរ